លេខ ១ ថ្ងៃ ១៥ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥០៣
ត្រូវនឹងថ្ងៃទី ១ ខែមករា គ.ស. ១៩៦១

# ពន្លឺពុទ្ធចក្រ

## ទស្សនាវដ្ដី ប្រចាំត្រីមាស

## នៃ

## ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ

# LA LUMIERE BOUDDHIQUE

REVUE TRIMESTRIELLE

DE

L'ASSOCIATION DES BOUDDHISTES-CENTRE

DU CAMBODGE

N° I.— Dimanche 1er Janvier 1961

P-K-36
1961-1

លេខ ១ ថ្ងៃ ១៥ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥០៣
ត្រូវនឹងថ្ងៃទី ១ ខែមករា គ.ស. ១៩៦១

# ពន្លឺពុទ្ធចក្រ

## ទស្សនាវដ្ដី ប្រចាំត្រីមាស

## នៃ

## ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ

# LA LUMIERE BOUDDHIQUE

REVUE TRIMESTRIELLE

DE

L'ASSOCIATION DES BOUDDHISTES-CENTRE

DU CAMBODGE

Nº I.— Dimanche Ier Janvier 1961

# ពន្លឺពុទ្ធចក្រ

ទស្សនាវដ្តីប្រចាំត្រីមាស

នៃ

ពុទ្ធិកសមាគម-មជ្ឈមណ្ឌលនៃប្រទេសកម្ពុជា

---

# LA LUMIÈRE BOUDDHIQUE

REVUE TRIMESTRIELLE

DE

L'ASSOCIATION DES BOUDDHISTES-CENTRE DU CAMBODGE

Nº 1.— Dimanche 1er Janvier 1961

ចាងហ្វាងនៃការផ្សាយ : រ៉ាយ-ល្មុត

បណ្ណាធិការ : ណង់-លន់

ទីសំណាក់ការបណ្ដោះអាសន្ន : វត្តឧណ្ណាលោមភ្នំពេញ

Directeur de publication : Ray-Lomuth

Gérant : Nong-Lonn

Siège provisoire : Watt Unnalom Phnom-Penh Cambodge

# ពន្លឺពុទ្ធចក្រ


| អត្ថបទ | មាតិការៀង | ទំព័រ |
|---|---|---|
| ១– និទានកថា | រៀបរៀងដោយលោក ក៉យ - លុត | |
| ២– ប្រវត្តិសង្ខេបនៃ ពុ.ម.ក. | រៀបរៀងដោយលោក ក៉យ - លុត | |
| ៣– សកម្មភាពនៃ ពុ.ម.ក. | រៀបរៀងដោយលោក ក៉យ - លុត | |
| ៤– ការគ្រប់គ្រងគណៈសង្ឃ | រៀបរៀងដោយសម្តេចព្រះមហាសុមេធាធិបតី | |
| ៥– ទិដ្ឋកថា | រៀបរៀងដោយព្រះមុនីកោសល | |

# [illegible]

| ទំព័រ | [illegible] | [illegible] |
|---|---|---|
| | [illegible] | [illegible] – ១ |
| | [illegible] | [illegible] – ២ |
| | [illegible] | [illegible] – ៣ |
| | [illegible] | [illegible] – ៤ |
| | [illegible] | [illegible] – ៥ |

# និទានកថា

ទស្សនាវដ្ដី «ពន្លឺពុទ្ធចក្រ» ជាអង្គការរបស់សមាគមមួយ ដែលមាននាមថា៖ ពុទ្ធិកសមាគមមជ្ឈមណ្ឌលភាតុជវង្ស, ហៅខ្លីត្រឹមតែ ពុទ្ធិកសមាគមភាតុជវង្ស, ប្រើអក្សរសង្ខេបថា ពុ.ម.ភា. ។ ទស្សនាវដ្ដីនេះចេញផ្សាយរៀងរាល់ត្រីមាស នូវសំឡេង គោលគំនិត សំដីចំមាត់ នៃពុទ្ធសាសនិកជនខ្មែរមួយក្រុមតាំងពីបព្វជិតតាំងគ្រហស្ថ ដែលជាសមាជិកនៃសមាគម ។ ពន្លឺពុទ្ធចក្រ ត្រូវប្រតិបត្តិការ ក្នុងក្របខណ្ឌនៃលក្ខន្តិកៈរបស់ ពុ.ម.ភា. ដើម្បីញ៉ាំងសមាគមឲ្យមានដំណើរការណ៍ល្អ ទៅតាមគោលបំណង, កម្មវត្ថុ និងគោលការណ៍ របស់ខ្លួនផង ដើម្បីបំពេញកិច្ចអនុវត្តខ្លះផង នូវបទបញ្ញត្តិមាត្រា ៨ នៃរដ្ឋធម្មនុញ្ញ ប្រទេសកម្ពុជា ដែលមានសេចក្ដីថា៖ ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ។

ពុ.ម.ភា. ជាសមាគមខាងពុទ្ធសាសនា ដែលរាជរដ្ឋាភិបាលបានទទួលស្គាល់ជាប្រយោជន៍សាធារណៈតាមព្រះរាជក្រឹត្យលេខ ២២៤.ភា.ប.រ.ឈ. ចុះថ្ងៃទី ៣ មិថុនា ព.ស.២៥០៣ / គ.ស.១៩៦០ ។

ពុ.ម.ភា. មានគោលបំណងនិងកម្មវត្ថុ ៦ ខ ដូចតទៅ៖

១– ឧបត្ថម្ភពពួកសមាជិក ក្នុងការយកចិត្តទុកដាក់ធ្វើតាម និងក្នុងការប្រតិបត្តិត្រឹមត្រូវតាមពុទ្ធោវាទ ;

២– កសាងធ្វើឲ្យមានឯកភាព, សាមគ្គីភាព និងភាតរភាព រវាងពុទ្ធមាមកជន ;

៣– ផ្សាយនូវអនុត្តរធម៌របស់ព្រះសម្ពុទ្ធបរមគ្រូ ;

៤– ចាត់ចែងធ្វើសកម្មភាពខាងប្រជាសង្គ្រោះ; ការសិក្សា, វប្បធម៌ និង កិច្ចការឯទៀតជាមនុស្សធម៌ ;

៥– ខំប្រឹងប្រែងធ្វើការកសាង ឲ្យមានសន្តិភាព និងសុខដុមរមនាមនុស្សជាតិផង ឲ្យមានសុភមង្គលដល់សត្វលោកផង ហើយរួបរួមជាមួយនឹងអង្គការឯទៀតដែលមានគោលបំណងដូចគ្នា,

៦– ចាត់ចែងឲ្យធ្វើដំណើរទៅទស្សនា បូជនីយដ្ឋាន, សង្គ្រោះដល់វត្ត ដែលចង់ទៅបំពេញវិជ្ជាខាងព្រះពុទ្ធសាសនា ឯប្រទេសក្រៅ ។

ពុ.ម.ភា. ឋិតនៅក្រោមព្រះបរមរាជូបត្ថម្ភនិងព្រះបរមរាជាធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូងនៃប្រទេសកម្ពុជា ហើយរួបរួមនូវសមាជិក ៥ ប្រភេទដូចតទៅ៖

១– សមាជិកកិត្តិយស បានដល់បណ្ដាឥស្សរជន ជាន់ខ្ពស់ដូចតទៅជាដើម គឺ៖ សម្ដេច

ព្រះសង្ឃនាយកទាំងពីរគណៈ, លោកអ្នកឧកញ៉ាប្រធានរដ្ឋសភា, ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ, នាយករដ្ឋមន្ត្រី...(ល);

២– ជនកសមាជិក គឺជាសមាជិកដែលបានរួបរួមជួយក្នុងការបង្កើត ពុ.ម.ក. ដោយបានបង់ប្រាក់ជូនសមាគមយ៉ាងតិចប្រាំរយរៀល (៥០០៛០០) ព្រមទាំងបង់ប្រាក់ភាគទានចំនួនដប់រៀល (១០៛០០) រៀងរាល់ខែ;

៣– នាយកសមាជិក គឺជាសមាជិកដែលបានធ្វើអំណោយជូនសមាគមយ៉ាងតិចពីរពាន់រៀល (២០០០៛០០)

៤– កម្មិកសមាជិក គឺជាសមាជិកដែលបង់ប្រាក់ភាគទានរៀងរាល់ខែ ចំនួនដប់រៀល (១០៛០០) ជូនសមាគម ។ សមាជិកប្រភេទនេះ តែងមានឆន្ទៈល្អជួយជានិច្ចកាល មិនថានៅទីណា កន្លែងណាឲ្យសមាគមបានចម្រុងចម្រើនឡើង ;

៥– បសាទិកសមាជិក គឺជាសមាជិកដែលមានសោមនស្សចំពោះសមាគម ហើយបានបរិច្ចាគបច្ច័យជូនសមាគម មួយលើកមួយគ្រាចំនួនតិចជាងពីរពាន់រៀល (២០០០៛០០) ។

ពុ.ម.ក. ប្រព្រឹត្តទៅ ក្រោមការត្រួតត្រានៃគណៈកម្មាធិការនាយកមួយដែលមានទីសំណាក់ការបណ្ដាះសាសន្ទ នៅវត្តឧណ្ណាលោម នាទីក្រុងភ្នំពេញ ។ គណៈកម្មាធិការនាយកចាត់ចែងការ ទៅតាមលក្ខន្តិកៈ នឹងបទបញ្ជាត្រឹមត្រូវរបស់សមាគម ដោយមានទីប្រឹក្សាយ៉ាងជំនាញៗ ខាងព្រះពុទ្ធសាសនា, គណៈកម្មការផ្សេងៗ ហើយនឹងគណៈកម្មាធិការខេត្ត, ស្រុក, ឃុំ ជួយធ្វើការផង ។

ពុ.ម.ក. បានធនធាន ដោយប្រាក់ភាគទាននៃសមាជិក, ទាន, ទេយ្យទាន, ជំនួយ, ផលនៃពិធីបុណ្យ, ឆ្នោតវត្ថុ, សទ្ធាទានផ្សេងៗ ពីឯកជនឬពីអង្គការសាធារណៈ ហើយនឹងប្រតិលាភផ្សេងៗ ។

ពុ.ម.ក. ធ្វើមហាសន្និបាតនៅទីក្រុងភ្នំពេញ នៅថ្ងៃណាមួយក្នុងដើមខែមករា រៀងរាល់ឆ្នាំ សេចក្តីម្យ៉ាងទៀតថា ធ្វើមហាសន្និបាត នៅឱកាស អនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃ ជ្រើសយកថ្ងៃណាមួយក្នុងកំឡុងពេលពីថ្ងៃ ១៥ កើត ទៅ ៥ រោច ខែបុស្ស ។ មហាសន្និបាត ត្រូវធ្វើទៅតាមរបៀបដូចមានចែងជាពិស្ដារក្នុងបទបញ្ជានៃសមាគមស្រាប់ ដើម្បីចាត់ការដូចតទៅ ៖

ក/ – ជ្រើសតាំងសមាជិកនៃគណៈកម្មាធិការនាយកសំរាប់ឆ្នាំថ្មី ;

ខ/ – ស្តាប់សេចក្តីរាយការណ៍របស់គណៈកម្មាធិការនាយក អំពីបញ្ហាទាំងឡាយដែលទាក់ទងនឹងសមាគម និងអំពីស្ថានភាពហិរញ្ញវត្ថុ ក្នុងឆ្នាំដែលកន្លងទៅហើយ ;

គ/ – ពិភាក្សាអំពីបញ្ហាទាំងអស់ដែលចុះក្នុងរបៀបវារៈ ហើយដែលគណៈកម្មាធិការនាយកចង់ស្នើសុំឲ្យមហាសន្និបាតបញ្ចេញមតិ ។

នៅពេលណាដែលមានការមមាញឹក គណៈកម្មាធិការនាយកនៃ ពុ.ម.កា អាចចាត់ការអញ្ជើញសមាជិកមករួមប្រជុំ ជាមហាសន្និបាតវិសាមញ្ញ ឬជាសមាជបន្ទាន់ ដើម្បី ៖

– ពិភាក្សាអំពីបញ្ហាសំខាន់ណាមួយ ដែលមានឡើងចំពោះសមាគម ;

– ស្នើសេចក្តីសង្កេត និងការជូនយោបល់គ្រប់យ៉ាងទៅគណៈកម្មាធិការនាយក ។

បើស្តីអំពីការរំលាយសមាគមវិញ ការនេះនឹងធ្វើបាន លុះណាតែមានភាគពីរក្នុងបី (២/៣) នៃចំនួនសមាជិក ដែលអញ្ជើញមករួមប្រជុំ ជាមហាសន្និបាត បញ្ចេញមតិយល់ព្រមផង ។ ប្រសិនបើមានការរំលាយ, សង្ហារិមៈនិងអសង្ហារិមៈទាំងឡាយរបស់ ពុ.ម.កា. ត្រូវមហាសន្និបាតបញ្ចេញមតិជាពិសេសថា ត្រូវចាត់ចែងយ៉ាងណា ៗ ។

ទង់របស់ ពុ.ម.កា. ជាទង់មានពណ៌ ៦ តម្រៀបនឹងឆព្វណ្ណរង្សីរបស់ព្រះសម្ពុទ្ធទុកជាមូលដ្ឋាន ។ រីឯត្រាសាទិសនៃ ពុ.ម.កា. គឺរូបធម្មចក្កមានកាំ ៨ តាងអរិយមគ្គមានអង្គ ៨ ។

សព្វថ្ងៃ សមាជិកនៃ ពុ.ម.កា. មានចំនួនដូចតទៅ ៖

– សមាជិកកិត្តិយស ៥ រូប ;

– ជនកសមាជិក ៤៣ " ;

– ទាយកសមាជិក ៥ " ;

– កម្មិកសមាជិក ៥៧៣ "

ឯបាសាទិកសមាជិក នោះមានចំនួនច្រើនពាន់ តែមិនរាប់កត់ចំនួនទេ ព្រោះសមាជិកប្រភេទនេះបានបង់ប្រាក់ជូនសមាគមមួយដងមួយកាលប៉ុណ្ណោះ ។

តាមសេចក្ដី ដូចរៀបរាប់ខាងលើ ឃើញថា ពុ.ម.គា. នៅទន់ខ្សោយនៅឡើយ ។ គណៈកម្មាធិការនាយកប្រចាំ ព.ស.២៥០៣ / គ.ស.១៩៦០ អំពាវនាវសូមពុទ្ធមាមកជនទូទៅ មេត្តាអនុគ្រោះដល់ ពុ ម.គា. តាមសទ្ធាជ្រះថ្លា ដើម្បីឲ្យសមាគមមានកម្លាំងបំពេញកិច្ចការតាមគោលបំណងរបស់ខ្លួន ឲ្យបានកាន់តែទូលំទូលាយតទៅព្រោះ ដូចបាននិទានរួចទៅហើយ, សមាគមនេះ គឺពិតជាសមាគម សាប ព្រោះ បណ្ដុះ ដាំពូជនៃសេចក្ដីស្ងប់ សេចក្ដីរៀបរយ នឹងសេចក្ដីស្រុះស្រួលគ្នា ក្នុងបណ្ដាមនុស្សជាតិ ហើយនឹងសេចក្ដីករុណាគ្រាប្រណីចំពោះ សត្វលោកទាំងអស់ ឥតឃ្លៀងឃ្លាតឡើយ ។

គណៈកម្មាធិការនាយក

## Adaptation française de l'Introduction du Comité-Directeur de l'Association des Bouddhistes - Centre du Cambodge.

(Traduite par M. RAY-LOMUTH)

La Revue **«La Lumière Bouddhique»** est l'organe d'une Association dénommée: **Asssociation des Bouddhistes Centre du Cambodge**; son appellation en bref est : **Association Bouddhique du Cambodge**; les initiales de ce nom sont : **A.B.C.C.** Cette Revue trimestrielle vulgarise la voix ou en d'autres termes, les assertions d'un groupe de Bouddhistes cambodgiens bonzes et laïcs membres de l'Association. **«La Lumière Bouddhique»** exerce ses activités dans le cadre des statuts de l'A.B.C.C afin de contribuer à la bonne marche de celle ci conformément à ses buts, objets et principes tout en consacrant, dans certaines mesures, les dispositions de l'article 8 de la Constitution du Royaume du Cambodge ainsi conçues: **le Bouddhisme est la Religion de l'Etat.**

L'A.B.C.C. est une Association que le Gouvernement Royal a reconnue d'utilité publique par Kret n° 224 C.D.E. du 3 Juin 1960.

L'A.B.C.C. se propose de poursuivre les six buts et objets suivants :

1—. Entretenir, entre les membres, la stricte observance et la pratique de l'Enseignement du Bouddha notre Maitre vénéré;

2—. Assurer l'unité, la solidarité et la fraternité entre les bouddhistes;

3—. Propager la Doctrine sublime du Bouddha;

4—. Organiser et poursuivre des campagnes d'activités sociales éducatives, culturelles et autres services humanitaires;

5—. Travailler à assurer la Paix et l'Harmonie entre les hommes et le bonheur de tous les Êtres et collaborer avec les autres organismes poursuivant les mêmes buts;

6—. Organiser des pélerinages et accorder des secours aux élites désireux de complèter leurs instructions bouddhiques aux pays étrangers.

L'A.B.C.C. est placée sous le Haut Patronage et sous la Haute Présidence de Sa Majesté le Roi du Cambodge et composée de cinq catégories de membres ci-dessous:

**1°.—Membres d'Honneur** dont la qualité est réservée notamment aux hautes personnalités suivantes : Leurs Eminences Samdech - Chefs des deux Ordres Bouddhiques, leurs Excellences le Président de l'Assemblée Nationale, le Président du Conseil du Royaume, le Président du Conseil des Ministres etc...;

**2.— Membres fondateurs** étant ceux qui contribuent à la création de l'A.B.C.C. en payant une contribution de cinq cents riels (500ȷ00) au moins et qui versent à l'Association une cotisation mensuelle de dix riels (10ȷ00);

**3.— Membres donateurs**. Ces catégories de membres versent à la caisse de l'Association un don de deux mille riels (2000ȷ00) au moins.

**4.— Membres actifs.** Ce sont ceux qui versent une cotisation mensuelle de dix riels(10ȷ00) au moins et qui, par leur bonne volonté, contribueut, à tout moment, au développement de l'Association.

**5.—Membres sympatisants.** Ces membres partageant la Doctrine et le programme de l'Association, aident celle-ci occasionnellement par leurs libéralités du montant de moins de deux mille riels (2000ȷ00).

L'A.B.C.C. est administrée par un Comité-Directeur ayant son siège provisoire au Mahakod de la pagode d'Onnalom à Phnom-Penh. Le Comité-Directeur fonctionne conformement aux Statuts et Règlements intérieurs légaux de l'Association et est assisté d'érudits conseillers, de commissions diverses et de Comités de Khet, de Srok et de Khum.

L'A.B.C.C. tire ses ressources des cotisations des membres, des dons, offres et subventions produits de fêtes, tombola et libéralités diverses des individus et des organismes publics et des revenus divers.

Les membres de l'A.B.C.C. se réunissent en Assemblée Générale dans le courant du mois de Janvier de chaque année, c'est-à-dire à l'occasion de l'Assemblée annuelle des bonzes de haute hierarchie ce conformément aux dispositions du Règlement intérieur de l'Association à l'effet :

a)— d'élire les membres du Comité-Directeur pour la nouvelle année;

b)— d'entendre les comptes-rendus du Comité-Directeur sur toutes les questions intéressant l'Association et sur la situation financière pendant l'année écoulée;

c)— de délibérer sur toutes les questions inscrites à l'ordre du jour et que le Comité-Directeur désire soumettre au vote de l'Assemblée.

En cas d'urgence, le Comité-Directeur peut convoquer les membres à se réunir soit en Assemblée Générale extraordinaire soit en Congrès pour :

— délibérer sur une question importante intéressant l'Association;

— soumettre au Comité-Directeur toutes sortes d'observations ou de suggestions.

En ce qui concerne la dissolution de l'Association, elle ne peut être réalisée que par un vote de l'Assemblée Générale à la majorité des deux tiers (2/3) au moins des membres présents. En cas de dissolution, les biens meubles et immeubles de l'A.B.C.C. recevront l'affectation qui sera fixée par un vote spécial de l'Assemblée Générale.

Le Drapeau de l'A.B.C.C. est un drapeau à six couleurs basées sur les Shadvarna Rasmi du Bouddha. Le Sceau commun de l'A.B.C.C. est le Dhamma Cakka avec huit rayons représentant les huits Voies sublimes.

L'A.B.C.C. se composent actuellement de :

— 5 membres d'honneur;

— 43 membres fondateurs;

— 5 membres donateurs;

—573 membres actifs.

Il est inutile de noter ici le nombre des membre sympatisants qui comptent plusieurs milliers, parce que cette catégorie de membres ne versent à l'Association que occasionnellement.

Par ce qui précède, on peut constater que l'Association est loin d'être prospère. Le Comité-Directeur de l'année 1960 fait donc appel à la charité des Bouddhistes en général pour que l'A.B.C.C. ait les moyens financiers de poursuivre ses nobles buts dans les mesures de plus en plus larges, car l'A.B.C.C. nous nous permettons de le répéter, est bien une Association qui sème la Paix, l'Ordre et la Concorde dans l'Humanité et la Compassion à tous les Etres.

*Le Comité-Directeur,*

# ប្រវត្តិសង្ខេប នៃពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ

ដោយលោក ក៉យ-លុត

កាលពីថ្ងៃទី ៦ មិថុនា ព.ស.២៤៩៤/គ.ស.១៩៥០, នៅទីក្រុងកោលម្ប (លង្កាទ្វីប) មានធ្វើសន្និសីទមួយ រួបរួមប្រជុំប្រទេសចំនួន ២៩ គិតទាំងកម្ពុជរដ្ឋយើងផង ។ ក្នុងពេលនោះ មានសម្តេចព្រះមហាសុមេធាធិបតី (ជួន-ណាត ជោតញ្ញាណោ) សង្ឃនាយកគណៈមហានិកាយ ជាប្រធាននៃគណៈប្រតិភូខ្មែរយើង ។

សន្និបាតនៃសន្និសីទបានអនុម័ត នូវអត្ថបទស្តីពីការរៀបចំបង្កើតនូវសមាគមមួយខាងពុទ្ធសាសនា ដែលមាននាមថា « ពុទ្ធិកសមាគមពិភពលោក » ដោយមានទីសំណាក់ការបណ្ដោះអាសន្ន នៅទីក្រុងកោលម្ប

ក្នុងអត្ថបទនោះ ត្រង់មាត្រា ១២ នឹង ១៨ ជាដើម មានសេចក្ដីថាពុទ្ធិកសមាគមពិភពលោកទទួលស្គាល់កម្ពុជរដ្ឋយើង ជាមជ្ឈមណ្ឌលភូមិភាគរបស់ខ្លួនផង ហើយជាជនកសមាជិកនៃមជ្ឈមណ្ឌលនោះផង

ក្នុងឋានៈនេះ កម្ពុជាយើងត្រូវបង់បច្ច័យ ចូលទៅពុទ្ធិកសមាគមពិភពលោករៀងរាល់ឆ្នាំជា៖

ក)– ប្រាក់បរិសទានប្រចាំឆ្នាំចំនួន ១.០០០ រូពី (រូពិយប្រាក់លង្កា);

ខ)– ប្រាក់ចំនួនម្ភៃប្រាំភាគរយ (២៥%) នៃប្រតិលាភរាល់ឆ្នាំ ដែលបានមកពីសមាជិករបស់ខ្លួនក្ដី ពីសាខាឬពីអង្គការ ដែលឡើងមកខ្លួនក្ដី ។

តមកក្រោមការណែនាំនៃសម្តេចព្រះមហាសុមេធាធិបតី ក្នុង ព.ស. ២៤៩៥ (គ.ស. ១៩៥១) មានធ្វើបុណ្យផ្កាមួយនៅសាលាបាឡីជាន់ខ្ពស់នាទីក្រុងភ្នំពេញ (ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត) រួបរួមបានបច្ច័យចំនួន ១៣.៦៣៧ រៀល ។ សម្តេចព្រះមហាសុមេធាធិបតី ក៏បានចាត់ការផ្ញើប្រាក់បរិសទានរបស់ភូមិភាគកម្ពុជរដ្ឋចំនួន ១ ០០០ រូពី (៤.៤០០ រៀល) ទៅពុទ្ធិកសមាគមពិភពលោក រួចជាស្រេចហើយសំរាប់ឆ្នាំ ១៩៥១ ។ ប្រាក់ដែលសល់ពីបុណ្យផ្កានេះ គឺ ៩.២៣៧ រៀល ត្រូវបង់ទៅក្នុងបេឡា នៃពុទ្ធិកសមាគមកម្ពុជរដ្ឋ ដែលទើបត្រូវបង្កើតឡើងនៅពេលខាងមុខជាបន្ទាប់ ។

តមកទៀត នៅថ្ងៃទី ១៤ មិថុនា ព.ស. ២៤៩៥ (គ.ស. ១៩៥២) ដោយសម្តេចព្រះមហាសុមេធាធិបតីបានផ្តួចផ្តើមគំនិតឡើង ក៏មានការជួបជុំបរិស័ទយ៉ាងកុះករ នៅវត្តឧណ្ណាលោម ជាមហាសន្និបាតពិសេសមួយ ។ ក្នុងឱកាសនោះ មហាសន្និបាតបានបោះឆ្នោតជ្រើសរើសគណៈកម្មាធិការនាយកបណ្ដោះអាសន្ន

ដែលមានភារៈរៀបចំលក្ខន្តិកៈរបស់មជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ ហើយគាត់ការត្រៀមមហាសន្និបាតជ្រើសតាំងគណៈកម្មាធិការនាយកជាស្ថាពរ ដើម្បីអនុវត្តលក្ខន្តិកៈនោះតទៅ ។

ដើម្បីសម្រួលការតទៅទៀត សម្ដេចព្រះមហាសុមេធាធិបតីបានមេត្តាអនុញ្ញាត ឲ្យសមាគមតាំងទីសំណាក់ការ នៅវិហារវត្តឧណ្ណាលោម ។

គណៈកម្មាធិការនាយកបណ្ដោះអាសន្ន បានខំប្រឹងប្រែងរៀបចំលក្ខន្តិកៈ បានរួចស្រេចជាភាសាខ្មែរ-បារាំង នៅថ្ងៃទី ២៤ កក្កដា ព.ស. ២៤៩៥ (គ.ស. ១៩៥២) ។ នៅថ្ងៃទី ១៩ សីហាឆ្នាំដដែល បានជូនលក្ខន្តិកៈនេះ ទៅដំកល់នៅសាលាវិនិច្ឆ័យ ត្រឹមត្រូវតាមព្រះរាជក្រមលេខ ១៦៧ ន.ស. ចុះថ្ងៃទី ១៥ មេសា គ.ស. ១៩៤៦ សេចក្ដីម្យ៉ាងទៀតថា នៅថ្ងៃ ១៤ កើតខែស្រាពណ៍ឆ្នាំរោងចត្វាស័ក ព.ស. ២៤៩៥ ខេមរជនមួយក្រុមបានបង្កើត នៅកម្ពុជរដ្ឋ នូវសមាគមខាងពុទ្ធសាសនាមួយដែលមាននាមថា « ពុទ្ធិកសមាគមពិភពលោក-មជ្ឈមណ្ឌលភូមិភាគ កម្ពុជរដ្ឋ » បើហៅខ្លីត្រឹមតែ « ពុទ្ធិកសមាគមកម្ពុជរដ្ឋ » បើប្រើអក្សរសង្ខេបថា « ពុ.ពិ.ម ភូ.ក » ។ ឯលក្ខន្តិកៈនោះ មានបោះពុម្ពផ្សាយជាសៀវភៅ មានចំនួនច្រើនពាន់ ក្បាលស្រាប់ ។

នៅថ្ងៃ ៤ កើតខែកត្តិកឆ្នាំរោងដដែល (៥ វិច្ឆិកា គ.ស. ១៩៥២) គណៈកម្មាធិការនាយកបណ្ដោះអាសន្ន បាននាំសេចក្ដីព្រាងនៃលក្ខន្តិកៈ ទៅក្រាបថ្វាយ ចំពោះព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម-សីហនុវរ្ម័នជាអម្ចាស់ជីវិតលើត្បូង ព្រះអង្គក៏ទ្រង់សព្វព្រះរាជហឫទ័យដ៏ក្រៃលែង នឹងការបង្កើតសមាគមនេះ ដែលមានប្រយោជន៍ធំដល់កម្ពុជរដ្ឋ ហើយទ្រង់បានទទួលដោយរីករាយ នូវព្រះរាជឋានន្តរជា ព្រះបរមរាជូបត្ថម្ភក៏ផង ជាព្រះបរមរាជាធិបតីផងនៃ ពុ.ពិ.ម.ភូ.ក. ដូចមានត្រាទុកក្នុងប្រការ ៣ នៃលក្ខន្តិកៈស្រាប់ ។ ក្នុងឱកាសនោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់បានព្រះរាជទានព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ជាបច្ច័យចំនួន៥០០០រៀល ដើម្បីបណ្ដុះសមាគមនេះ ឲ្យបានលូតលាស់ចំរើនជាគិយោភាពតទៅ ហើយទ្រង់មានព្រះរាជឱង្ការផ្ដែផ្ដាំថា បើសមាគមត្រូវការដែលទ្រង់អាចជួយបាន នោះព្រះអង្គនឹងខំប្រឹងប្រែងជួយ លុះត្រាតែបានសម្រេចតទៅ ។

អំណើះតពីព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម-សីហនុវរ្ម័នមក ព្រះមហាក្សត្រិយ៍ទ្រង់រាជសម្បត្តិនៅកម្ពុជរដ្ឋ ព្រះអង្គជាព្រះបរមរាជូបត្ថម្ភក៏នឹងជាព្រះបរមរាជាធិបតី នៃពុទ្ធិកសមាគមកម្ពុជរដ្ឋ ជាប្រពៃណីរហូតដល់សព្វថ្ងៃនេះ ។

តមក ដោយអនុលោមទៅតាមប្រការ ៣០ នៃរក្ខន្តិកៈ គណៈកម្មាធិការនាយកបណ្ដោះអាសន្ន បានចាត់ការប្រជុំមហាសន្និបាត នៅថ្ងៃទី ២៨ ធ្នូ គ.ស. ១៩៥២ ។ នៅឱកាសនោះ មហាសន្និបាតបានអនុម័តទទួលយក នូវសេចក្ដីព្រាងលក្ខន្តិកៈ ហើយបានជ្រើសតាំងគណៈកម្មាធិការនាយកជាស្ថាពរ សំរាប់ឆ្នាំ-១៩៥៣ ដើម្បីប្រតិបត្តិការតទៅ ។ តាំងពីពេលនោះមក ជាលំដាប់រៀងរាល់ឆ្នាំ ពុទ្ធិកសមាគមកម្ពុជរដ្ឋ បានប្រជុំមហាសន្និបាតផ្លាស់ប្ដូរ សមាសភាពនៃគណៈកម្មាធិការនាយកប្រចាំឆ្នាំដែលមានសេចក្ដីពិស្ដារនៅទំព័រខាងមុខស្រាប់ ។

ខ្ញុំសូមកត់សំគាល់ថា មហាសន្និបាតទី ៦ នាថ្ងៃទី ៧ មករា គ.ស. ១៩៥៨ បានបញ្ចេញមតិជាឯកច្ឆន្ទទទួលយកនូវសេចក្ដីសម្រេចចិត្តមួយថា បានការមានសេចក្ដីថា ពុទ្ធិកសមាគមពិភពលោក មជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ ឬ ពុទ្ធិកសមាគមកម្ពុជរដ្ឋ ឬ ពុ.ពិ.ម.ភូ.ក. ត្រូវប្រែនាមថា ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ ឬ ពុទ្ធិកសមាគមកម្ពុជរដ្ឋ ឬ ពុ.ម.ក វិញ ។ សមាគមដែលមាននាមថ្មីនេះ ត្រូវមានស្វ័យភាពពេញបរិបូណ៌ ដោយហេតុថា តាំងពីសមាគមនេះបានបង្កើតឡើង (គ.ស.១៩៥២) រហូតមកដល់គ.ស.១៩៥៨ គឺក្នុងរយៈពេល ៧ ឆ្នាំ នោះឥតមានការទាក់ទងអ្វីណាមួយទាល់តែសោះ រវាងពុទ្ធិកសមាគមកម្ពុជរដ្ឋ នឹងពុទ្ធិកសមាគមពិភពលោកនៅទីក្រុងកោលម្បូ (លង្កាទ្វីប) ទោះពុទ្ធិកសមាគមកម្ពុជរដ្ឋផ្ញើបច្ច័យទៅចូលជាភាគទានក៏ ផ្ញើសំបុត្រទៅប្រាស្រ័យយ៉ាងណាក្ដី ក៏សមាគមឥតបានទទួលសេចក្ដី ឆ្លើយអ្វីសោះ ពីពុទ្ធិកសមាគមពិភពលោក ។

## Résumé de l'Histoire de l'Association des Bouddhistes-Centre du Cambodge

(Traduite par M. RAY-LOMUTH)

Le 6 Juin 1950 eut lieu à Colombo (Ceylan) une conférence de 29 pays y compris le Cambodge. A cette occasion, la Délégation du Cambodge était présidée par son Eminence le Samdech Préah Maha Sumédhadhipati Chef de l'Ordre Mahanikay (Chuon-Nath) jotanhano.

La Conférence a adopté les textes portant création d'une Association Bouddhique dénommée : « L'Association Mondiale des Bouddhistes (THE WORLD FELLOWSHIP OF BUDDHISTS).

De par ces textes, notamment les dispositions des articles 12 et 18 spécifient que l'Association Mondiale des Bouddhistes reconnaît le Cambodge comme un de ses Centres Régionaux et comme un membre fondateur de ce Centre. Or en cette qualité, le Cambodge doit verser à l'Association Mondiale des Bouddhistes :

1.— une souscription annuelle de mille roupies (monnaie de Ceylan);

2.— une cotisation annuelle égale à 25 °/₀ du montant des revenus provenant de ses membres et de ses succursales ou organisations affiliées.

Par la suite, sur l'initiative de Son Eminence le Samdech Préah Maha Sumédhadhipati, a été organisée en 1951, à l'Ecole Supérieure de Pali à Phnom-Penh (appellation actuelle : « Lycée Bouddhique Préah Suramarit » ), une fête de Phka dont le produit s'élevait à 13.637 riels. Samdech a fait faire le nécessaire concernant l'envoi à l'Association Mondiale des Bouddhistes à Ceylan de la somme de 1.000 roupies (4.400 riels) représentant le montant de la souscription du Centre Régional du Cambodge pendant l'année 1952. Le reliquat soit 13.637 - 4.400=9.237 riels sera versé à la Caisse de l'Association Bouddhique du Cambodge, Association à créer prochainement.

Peu de temps après, c'est-à-dire le 14 Juin 1952, sur l'initiative de Samdech Préah Maha Sumédhadhipati, plusieurs centaines de bouddhistes se sont réunis à la pagode d'Onnalom à Phnom-Penh en une Assemblée Extraordinaire à l'issue de laquelle, il a été élu un Comité-Directeur provisoire chargé de l'élaboration des Statuts du Centre Régional du Cambodge, puis de convoquer une Assemblée Générale pour l'élection d'un Comité-Directeur définitif en vue de mettre ces Statuts en application.

Dans le but de faciliter le fonctionnement de l'Association, Samdech Préah Maha Sumédhadhipati a daigné autoriser celle-ci à installer provisoirement son Siège au Maha Kod de la pagode d'Onnalom.

Le Comité-Directeur provisoire a terminé son travail d'élaboration des Statuts en Cambodgien et en français le 24 Juillet 1952. Le 19 Août suivant, ces Statuts ont été déposés au Sala Vinichhay conformément aux dispositions du Kram n° 167 N.S. du 15 Avril 1946, en d'autres termes le 14ᵉ jour de la lune décroissante du mois de Srap de l'année de Rong (Naga) de l'Ere bouddhique 2495, un groupe de cambodgiens a créé au Cambodge une Association dénommée : **« Association Mondiale des Bouddhistes - Centre Régional du Cambodge»**; son appelation en bref est : **«Association Bouddhique du Cambodge»**; les initiales de ce nom sont : « A.M.B.C.R.C. » Plusieurs milliers de ces statuts ont été imprimés et publiés.

Le 5 Novembre 1952 le Comité-Directeur provisoire a soumis le projet des Statuts à Sa Majesté Préah bat Samdech Préah Norodom Sihanouk Varman qui a daigné accorder Son Haut agrément à la création de cette Association qui sera d'une grande utilité pour le Cambodge en même temps que Son Haut patronage et Sa Haute présidence à cette Institution ainsi qu'il est spécifié à l'article 3 de ses Statuts. A cette occasion, Sa Majesté a offert à cet organisme, de Sa Cassette personnelle, un don de 5.000 riels destiné à contribuer à son développement et a promis de l'aider dans tout ce qui Lui est possible de le faire. Et depuis, les Rois qui succèdent à Sa Majesté Norodom Sihanouk Varman prennent, de coutume jusqu'à ce jour, le Haut Titre de Protecteur et de Président de l'A.B.C.C.

Conformément aux dispositions de l'article 30 des Statuts, le Comité-Directeur provisoire a convoqué l'Assemblée Générale le 28 Décembre 1952 laquelle s'est prononcée sur l'adoption du projet des Statuts et a élu le Comité-Directeur définitif pour l'année 1953 en vue du fonctionnement de l'A.B.C.C. A partir de cette date, l'A.B.C.C. se réunit annuellement en Assemblée Générale et procède au renouvellement du Comité-Directeur dont la composition de chaque année est donnée en détail dans les pages qui suivent (1).

Je note, en passant, que la 6ᵉ Assemblée Générale du 7 Janvier 1958 a adopté, à l'unani-

(1) Voir en cambodgien.

mité, une résolution fixant la nouvelle dénomination de cette Association comme suit : « **L'Association des Bouddhistes - Centre du Cambodge** »; son appellation en bref est : «**Association Bouddhique du Cambodge** »; les initiales de ce nom sont A.B.C.C. L'Association sous cette nouvelle appellation jouit de sa pleine autonomie, car depuis sa création en 1952 jusqu'en 1958 c'est-à-dire pendant 7 ans, aucune relation n'a eu lieu entre l'Association Mondiale des Bouddhistes à Ceylan et l'Association mondiale des Bouddhistes - Centre Régional du Cambodge malgré que celle-ci envoie à la première sa souscription annuelle et ses nombreuses correspondances qui toutes demeurent sans réponse.

# សកម្មភាព នៃ ពុ.ម.ក.

តាំងពី ពុ.ម.ក. បានបង្កើតឡើងនៅ ព.ស.២៤៩៥ / គ.ស.១៩៥២ មកដល់ ព.ស.២៥០៣ / គ.ស.១៩៦០ ក្នុងបណ្ដាសកម្មភាពជាច្រើន សុទ្ធសឹងជាការកុសលទាំងអស់ត្រឹមត្រូវទៅតាមព្រះបរមពុទ្ធោវាទ ដែលសមាគមបានធ្វើ យើងសូមស្រង់សកម្មភាពខ្លះ មកចុះក្នុងទស្សនាវដ្ដីនេះ ទុកជាទីរលឹក ហើយរែកយកតែទៅគឺៈ

១– នៅក្នុងទិវាសភាពេលប្រជុំធំទាថ្ងៃទី ៦ កញ្ញា ព.ស.២៥០៣ / គ.ស.១៩៦០, ដោយអនុលោមទៅតាមបទបញ្ញត្តិប្រការ ១៣ នៃលក្ខន្តិកៈ របស់សមាគម, គណៈកម្មាធិការនាយកនៃ ពុ.ម.ក. បានបង្កើតគណៈកម្មការមួយ ហៅថាៈ គណៈកម្មការឃោសនាការដើម្បីបោះពុម្ពផ្សាយ ដែលមានការៈ ជាអាទិ៍ ចាត់ចែងការផ្សាយក្នុងបរិមណ្ឌលនូវទស្សនាវដ្ដី "ពន្លឺពុទ្ធចក្រ" នេះ ។

## ឯសមាសភាពនៃគណៈកម្មការនេះគឺៈ

### ក– ផ្នែកខាងបព្វជិត

១– សម្ដេចព្រះមហាសុមេធាធិបតី ជ-ណ.ជោតញ្ញាណោ សង្ឃនាយកគណៈមហានិកាយ ប្រធានកិត្តិយស

| | | | | | |
|---|---|---|---|---|---|
| ២– ព្រះពោធិវង្ស | ហួត-តាត | វជិរប្បញ្ញោ | អគ្គាធិការពុទ្ធិកសិក្សា | | សមាជិក |
| ៣– ព្រះធម្មលិខិត | ម៉ឹង-សែស | ចន្ទធម្មោ | ចៅអធិការវត្តមហាមន្ត្រី | | – |
| ៤– ព្រះមុនីកោសល | សួរ-ហាយ | សុវណ្ណសរោ | ,, | ឧណ្ណាលោម | – |
| ៥– ព្រះឃោសធម្ម | គៅ-ស៊ឹម | សីរិបញ្ញោ | ចៅអធិការ ,, | លង្កា | – |
| ៦– ព្រះសិរីសម្មតិវង្ស | ពជ-កឹង | សុវណ្ណកេសរោ | ,, | សារាវ័ន | – |
| ៧– ព្រះឧបាលិវង្ស | កែវ-ពន់ | សុវណ្ណគេហោ | ,, | ឧណ្ណាលោម | – |
| ៨ ព្រះពុទ្ធវង្ស | កឹម-គូ | បទុមង្គលោ | ,, | – | – |
| ៩– ព្រះទេពមុនី | ប្រាជ្ញ-ប៉ុល | សុវណ្ណប្បញ្ញោ | ,, | – | – |
| ១០– ព្រះសិរីសុទ្ធ | ធន់-ពន់ | ធម្មប្បញ្ញោ | ,, | – | – |
| ១១– ព្រះឥន្ទមុនី | សេខ-នាង | សារញ្ញាណោ | ,, | – | – |
| ១២– ព្រះគ្រូសង្ឃសត្ថា | ប៉ុណ្ណ-សុភាជ | ធម្មាភោ | ,, | – | – |
| ១៣– ព្រះគ្រូវិរិយមុនី | ជាប-ប្រាង | ឥន្ទប្បញ្ញោ | ,, | សារាវ័ន | – |

| | | | | | | |
|---|---|---|---|---|---|---|
| ១៤– | ព្រះមហា | សោម-ងន | ញាណប្បទីបោ | វត្ត | ឧណ្ណាលោម | សមាជិក |
| ១៥– | ព្រះភិក្ខុ | ប៉ាង-ខាត់ | វីរិយបណ្ឌិតោ | – | ឧណ្ណាលោម | – |
| ១៦– | ព្រះគ្រូបណ្ណាវត្តមុនី | សុរីយ៍ | ធម្មញាណោ | – | – | – |
| ១៧– | ព្រះវិនយធរ | អ៊ុម-ស៊ុម | សង្ឃត្តេពេ | – | សារាវ័ន | – |

## ១– ផ្នែកខាងគ្រហស្ថ

| | | | |
|---|---|---|---|
| ១– | លោក | ក៉យ-លុត | ចាងហ្វាងនៃការផ្សាយ |
| ២– | – | រស់-ហែម | សមាជិក |
| ៣– | – | មែរ-ប៉ាន់ | – |
| ៤– | – | ផា-ទន់ | – |
| ៥– | – | គួប-គីឡេង | – |
| ៦– | – | ជី-ទ្យាត់ | – |
| ៧– | – | ហ៊ុយ-អ៊ួប | – |
| ៨– | – | ញូង-ជាន | – |
| ៩– | – | ស៊ុយ-ហ៊ី | – |
| ១០– | – | កែន-ក្រុប | – |
| ១១– | – | តូន-សុខេត | – |
| ១២– | – | ទា-គីមឡុង | – |
| ១៣– | – | ពូង-សឿង | – |
| ១៤– | – | យូរ-អ៊ុន | – |
| ១៥– | – | ស្រី-អ៊ូ | – |
| ១៦– | – | ព៉ាក-ថៃម | – |
| ១៧– | – | សៅ-វ៉ៃន | – |
| ១៨– | – | ទង-លន់ | បណ្ណាធិការ |

ដោយមូលនិធិអាស៊ីជួយឧបត្ថម្ភផង និស្សិតដែល ពុ.ម.គ. ទំនុកបំរុងដោយជួយផ្តល់អាហារូបករណ៍មានពីរប្រភេទដូចតទៅ ៖

ក – និស្សិតដែលសមាគមកំពុងផ្តល់អាហារូបករណ៍សព្វថ្ងៃនេះគឺ ៖

១– លោកភិក្ខុ គង់-គូ (បិយសីលោ) មហាវិទ្យាល័យ ដេល្ហី ក្រុង ដេល្ហី ប្រទេសឥណ្ឌា ;

២– „ ឆាយ-ជន (ផលញ្ញាណោ) „ វិស្វភារតី ក្រុងបេង្គាល់ „ ;

៣– „ តោ-អាន (អគ្គរតោ:) „ សំស្ក្រឹត ក្រុងពារាណសី „ ;

៤– „ លី-គិមឡួង (អគ្គធីរោ) „ លង្កា ប្រទេសលង្កា ;

៥– „ វង់-គីមឡេង (ញាណសំវរោ) „ ធម្មទូត ក្រុងរង្គូនប្រទេសភូមា ;

៦– លោកសាមណេរ នូ-សុវៀគាត(សន្តិបាលោ) អនុវិទ្យាល័យ ស្តាហ្វរដ៍ ក្រុងកោលម្បូ ប្រទេសលង្កា ;

៧– លោក អៀង-មាន អនុវិទ្យាល័យវ៉លហ្សាប់ ក្រុងបុមបៃ ប្រទេសឥណ្ឌា ។

ខ– និស្សិតផ្សេង ៗ គឺ ៖

១– លោក គួច-គីឡេង អតីតនិស្សិតនៃមហាវិទ្យាល័យ គិរោរិមល ក្រុង ដេល្ហី ប្រទេសឥណ្ឌា បានត្រឡប់មក កម្ពុជរដ្ឋវិញហើយ សព្វថ្ងៃធ្វើជាសាស្ត្រាចារ្យនៅ ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ទីក្រុងភ្នំពេញ ៖

២– សីលវតី សិរីសោភិន (ម:បរមញ្ញាណី) អតីតនិស្សិតនៅ គោងខេ្យាងទីក្រុងរង្គូន (ប្រទេសភូមា) សព្វថ្ងៃលែងទទួលអាហារូបករណ៍ ពី ពុ.ម.គ. ហើយ ព្រោះទៅបន្តវិជ្ជាឯប្រទេសបារាំង ឥឡូវនេះត្រឡប់មកប្រទេសខ្មែរវិញហើយ ។

៣– ពីថ្ងៃទី ៩ ដល់ទី ១០ តុលា $\frac{\text{ព.ស.២៤៩៥}}{\text{គ.ស.១៩៤២}}$ កងឧកាសពិធីបុណ្យព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធបរមគ្រូ ព្រមទាំងព្រះអរហន្តធាតុនៃព្រះអគ្គសាវកទាំងគូពោលគឺ ព្រះមហាសារីបុត្រ និងព្រះមហាមោគ្គល្លាន ដែលបានអណ្តែតត្រសែគតី (ប្រទេសឥណ្ឌា) មកប្រតិស្ឋានទៅកម្ពុជរដ្ឋយើងដោយសេចក្តីសុំនៃ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម-សីហនុវរ្ម័ន ព្រះចៅព្រះរាជអាណាចក្រកម្ពុជា, សមាជិកនៃគណៈកម្មាធិការទាយកបណ្តោះអាសន្នរបស់សមាគមយើង បានខ្វល់ខ្វាយទាំងយប់ទាំងថ្ងៃ ឥតបន្ធូរបន្ថយ ទាំង

កំឡាំងទ្រព្យ-កាយ-ចិត្ត ជួយរាជរដ្ឋាភិបាលចាត់ការដោយពេញសមត្ថភាព ចប់ចុងចប់ដើម ក្នុងសេចក្ដីរៀបរយថ្នុថ្នរជាទីបំផុត ។ យើងរកគ្រប់មិនកើតថាក្នុងឱកាសពិធីបុណ្យនេះ គណៈកម្មាធិការនាយកបណ្ដោះអាសន្ន បានបំពេញកិច្ចប្រាស្រ័យយ៉ាងថ្លៃថ្លា ជាអាទិ បានរៀបចំលៀងគេសជ្ជៈ ចំពោះគណៈប្រតិភូខាងពុទ្ធសាសនានៃប្រទេសឥណ្ឌា, ភូមា, ថៃ, លាវ, វៀតណាម ។ គណៈប្រតិភូទាំងនោះ មានសេចក្ដីរីករាយក្រៃលែង ហើយបានជូនពរសព្វសាធុការ មកខ្មែរយើងជាអនេក ។

៨– ពីថ្ងៃទី ១២ ដល់ទី ១៨ ឧសភា ព.ស.២៥០០ / គ.ស.១៩៥៧ ក្នុងឱកាសពិធីបុណ្យព្រះពុទ្ធសករាជ ២៥០០ នៅទីក្រុងភ្នំពេញ ដែលមានសាងព្រះសាក្យមុនីចេតិយ នៅមុខរាជអយស្ម័យយាន ទុកជាអនុស្សាវរីយ៍ រហូតដល់សព្វថ្ងៃនេះស្រាប់, គណៈកម្មាធិការនាយកនៃសមាគមយើង បានទទួលភាគមួយយ៉ាងធំ នៃកិច្ចការដែលមានចែងក្នុងកម្មវិធីបុណ្យ ក្នុងសេចក្ដីរៀបរយថ្នុថ្នរសមរម្យជាទីបំផុត ជំរុញនឹងរាជរដ្ឋាភិបាល នាំឲ្យពិធីបុណ្យនេះ បានរុងរឿងជាកិយ្យភាគាព ។ ហើយចំណេរកាលតមក មានព្រះរាជក្រឹត្យលេខ ៧៣ ន.ស. ចុះទី ២១ មករា គ.ស. ១៩៥៨ បានបញ្ញត្តឲ្យធ្វើពិធីបុណ្យនមស្ការព្រះសាក្យមុនីចេតិយនេះ ទុកជាបុណ្យជាតិរៀងរាល់ឆ្នាំ នៅថ្ងៃពេញបូណ៌មី នឹង ១ រោចខែវិសាខ ក៏សមាគមបានចាត់ការ ក្នុងផ្នែកដែលរាជរដ្ឋាភិបាលប្រគល់មកឲ្យខ្លួន ដោយយកចិត្តទុកដាក់សម្រេចការឥតខ្ចោះរបស់ខ្លួន រហូតដល់សព្វថ្ងៃនេះ ។

៩– ថ្ងៃ ៧ កើតខែចេត្រ ឆ្នាំកុរឯកស័ក ព.ស. ២៥០២ (៣ មេសា គ.ស. ១៩៦០) ជាថ្ងៃដែលពុទ្ធិកសមាគមកម្ពុជរដ្ឋមានទុក្ខជាទម្ងន់ ដោយព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម - សុរាម្រិត ព្រះចៅព្រះរាជអាណាចក្រកម្ពុជា ដែលទ្រង់ជាព្រះបរមរាជូបត្ថម្ភក៍ ទាំងជាព្រះបរមរាជាធិបតី ជាទីគោរពសក្ការៈរបស់សមាគមយើង ទ្រង់សោយព្រះទិវង្គត ។ នៅថ្ងៃទី ៣ ឧសភា គ.ស. ១៩៦០ គណៈកម្មាធិការនាយកបានចាត់ការបង្សុកូល ឧទ្ទិសថ្វាយព្រះរាជកុសល ចំពោះព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ ។ នៅថ្ងៃ ៣ កើតខែភទ្របទ ឆ្នាំជូតទោស័ក ព.ស. ២៥០៣ (២៤ សីហា គ.ស ១៩៦០) ជាថ្ងៃថ្វាយព្រះភ្លើងចំពោះព្រះបរមសព សមាគមយើងបានចាត់ការបោះពុម្ពព្រះបរមឆាយាលក្ខណ៍ព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ ចំនួន ៥០០០ សន្លឹក ចែកជាសាធារណៈ ដើម្បីសំដែងសេចក្ដីក្រៀមក្រំសោកស្ដាយនៃពុទ្ធិកសមាគមកម្ពុជរដ្ឋ ។ ចំពោះរឿងនេះ តាមព្រះរាជសារលិខិតលេខ ៥១៣ . S.O. ចុះថ្ងៃទី ៦ កញ្ញា គ ស. ១៩៦០ សម្ដេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ទ្រង់បានសំដែងព្រះរាជអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ពុ.ម.គក. ហើយទ្រង់បួងសួងសូម

សមាជិកគ្រប់រូបនៃសមាគមនេះ បានប្រកបដោយព្រះពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពល ជានិច្ចនិរន្តរ៍ តទៅ ។

៦) សាខាបច្ចុប្បន្នរបស់ ពុ.ម.ភា. មានដូចតទៅ ៖

១ – គណៈកម្មាធិការស្រុកសម្បូណ៌ (ខេត្តក្រចេះ) ទីសំណាក់ការបណ្ដោះអាសន្ននៅវត្តព្រះវិហារធំ

២ – គណៈកម្មាធិការ ខេត្តព្រៃវែង ទីសំណាក់ការបណ្ដោះអាសន្ននៅវត្តសាំងសាមី

៣ – គណៈកម្មាធិការ ខេត្តស្វាយរៀង ទីសំណាក់ការបណ្ដោះអាសន្ននៅវត្តជម្ពូព្រឹក្សា ។

៤ – គណៈកម្មាធិការ ស្រុកកំពង់ត្រឡាច . . . . . . . . ដ . . . . . . . . . . នៅវត្តកំពង់ត្រឡាចក្រោម ខេត្តកំពង់ឆ្នាំង ,

## សមាសភាពនៃគណៈកម្មាធិការនាយកបណ្ដោះអាសន្ន

*ដែលមហាសន្និបាតពិសេសបានជ្រើសតាំងពីថ្ងៃទី ១៤ មិថុនា គ.ស. ១៩៥២*

ប្រធាន លោក ឡាំ-ឯម

អនុប្រធានទី ១ „ សម-ញាណ

„ ២ „ ក៏យ-ណេត

„ ៣ „ គាន់-ពូហេង

អគ្គលេខាធិការ „ ហ៊ុន-ឌី

លេខាធិការទី ១ „ ម៉ីញ-ណាគ្រី

„ ២ „ សម-ថាំង

អគ្គហេរញ្ញិក „ រស់-ហែម

ហេរញ្ញិកទី ១ „ ពុធ-អ៊ុម

„ ២ „ ស្វាយ-កា

សវនការ „ ជុំ-មួង, លោកហែន-កៀក,

លោក អ៊ុង-ទួន. លោកតាប-ពិន, លោកម៉ៅ-មុំ, លោក ទា-ផាវលី,

លោក អ៊ឹង-គីមង៉ន, លោក មាស-ម៉ន, លោក ជុំ-ឡូត

## សមាសភាពនៃគណៈកម្មាធិការនាយក

ដែលមហាសន្និបាតទី ១ បានជ្រើសតាំងពីថ្ងៃទី ២៨ ធ្នូ គ.ស. ១៩៥២ សំរាប់ឆ្នាំ ១៩៥៣

| | |
|---|---|
| ប្រធាន: | លោក ពាយ-លក |
| អនុប្រធានទី ១ | លោក អ៊ុក-ធុច |
| -ដ- ទី ២ | " ស្វាយ-សួរ |
| -ដ- ទី ៣ | " ជុំ-មួន |
| អគ្គលេខាធិការ | " សម-ថាំង |
| លេខាធិការ | " មុំញ-ណាគ្រី |
| -ដ- | " ស្វាយ-ពា |
| អគ្គហេរញ្ញិក | " រស់-ហៃម |
| ហេរញ្ញិក | " ពុធ-អ៊ុម |
| ហេរញ្ញិក | " ហ៊ុន-ឌី |

ស្នងការ៖ លោក សម-ញាណ, ហ៊ុយ-ម៉ោង, ឡុង-ទូច, តា-ដាវលី, តាន់-ចូហេង, ជុំ-ឡូត, អ៊ឹង-គីមង៉ន, ប៉ែន-ផាត់, ប៊ុន-ចន្ទម៉ុល, មាស-ម៉ន, ប៊ុក-សំអាន, ប៊ុន-ថាន់, អ៊ឹង-ទួន, ញាណ-សាត

## សមាសភាពនៃគណៈកម្មាធិការនាយក

ដែលមហាសន្និបាតទី ២ បានជ្រើសតាំងពីថ្ងៃទី ១០ កុម្ភៈ ១៩៥៥

សំរាប់ឆ្នាំ ១៩៥៤

ប្រធាន លោក អ៊ុក-ជុំ

អនុប្រធានទី ១ „ ពយ-លុត

អនុប្រធានទី ២ ឃុនព្រះម្ចាស់យ៉ិន-គាត

អនុប្រធានទី ៣ លោក ជុំ-មួង

អគ្គលេខាធិការ „ សម-ថាំង

លេខាធិការ „ ឡុង-ឌួប និងលោក ជុំ-ទួត

អគ្គហេរញ្ញិក „ រស់-ហៃម

ហេរញ្ញិក „ ពុធ-អ៊ុម និងលោក មាស-ម៉ន

ស្នងការ „ ម៉ុញ-ណាគ្រី, ទា-ផាវលី, គាន់-ចូហេង, អ៊ឹង-គឹមង៉ន, ប៊ុន-ចន្ទម៉ុល, ប៊ុន-ថាន់, ជូ-តិចស្រេង, ឈឹម-ស៊ុម, លោកស្រី ពយ-លុត និងលោកស្រី អ៊ឹង-គីមង៉ន

## សមាសភាពនៃគណៈកម្មាធិការនាយក

ដែលមហាសន្និបាតទី ៣ បានជ្រើសតាំងពីថ្ងៃ ៩ មករា ១៩៥៥

សំរាប់ឆ្នាំ ១៩៥៥

ប្រធាន លោក សម-ញាណ

អនុប្រធានទី ១ „ ពយ-លុត

-ដ- ទី ២ „ ប៉េ-យាន

-ដ- ទី ៣ „ ឃោក-ម៉ែន

អគ្គលេខាធិការ „ អ៊ុង-ទួន

លេខាធិការ „ ហ៊ុន-ឌី, ម៉ៅ-ម៉ុ

អគ្គហេរញ្ញិក „ រស់-ហៃម

លេខាធិការ ទី ១ លោក ពុធ - អ៊ុម
-ដ- ទី ២ „ មាស - ម៉ន
ស្នងការ „ ទា - គីមឡុង, នូ - ឯម, អ៊ឹង - គីមង៉ន,
តាន់ - ចូហេង, លោកស្រី ប៉ាយ - លុត

## ទីប្រឹក្សា:

១ - សម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ
២ - សម្ដេចព្រះធម្មលិខិតឧត្ដមប្រឹក្សា ល្វី-ឯម វត្ត លង្កា
៣ - ព្រះពោធិវង្ស ហួត - តាត (វជីរប្បញ្ញោ) „ ឧណ្ណាលោម
៤ - ព្រះមហាព្រហ្មមុនី ទេ - អ៊ួ (ថិតវីរយោ) „ ស្វាយពពែ
៥ - ព្រះឧបាលិវង្ស សួរ - ហាយ (សុវណ្ណសរោ) „ ឧណ្ណាលោម
៦ - ព្រះមហាវីរយបណ្ឌិតោ ប៉ាង - ខាត់ „ „
៧ - ព្រះធម្មត្រៃលោកាចារ្យ ក - តោ (ថិតសីលោ) „ បទុមវតី
៨ - ព្រះពុទ្ធវង្ស កៅ - ស៊ុម (សិរីបញ្ញោ) „ លង្កា
៩ - ព្រះវិន័យសង្វរពង - កឹង (សុវណ្ណកេសរោ) „ សារាវ័ន
១០ - ព្រះគ្រូសង្ឃសត្ថា ប៉ុណ្ណ - សុក្កាដ (ធម្មាភរោ) „ ឧណ្ណាលោម

## សមាសភាពនៃគណៈកម្មាធិការនាយក

ដែលមហាសន្និបាត ទី ៤ បានជ្រើសតាំងពីថ្ងៃទី ១០ មករា ១៩៥៦

សំរាប់ឆ្នាំ ១៩៥៦

ប្រធាន លោក សម-ញាណ
អនុប្រធានទី ១ „ ប៉ាយ - លុត
-ដ- ទី ២ „ ទេស - យ៉ន់

អនុប្រធាន ទី ៣ លោក យុង-យ៉ា

អគ្គហេរញ្ញិក " រស់-ហែម

ហេរញ្ញិក ទី ១ " បេ-យាន

—ដ— ទី ២ " មាស-ម៉ន

អគ្គលេខាធិការ " អ៊ុង-ទួន

លេខាធិការ " គា-គីមឡុង, ពុធ-អ៊ុម

ស្នងការ " ហ៊ុន-ឌី, តាន់-ប៊ូហេង, អ៊ឹង-គីមងន,

លោកស្រី ប៉យ-លុត នឹងលោកស្រី អ៊ឹង-គីមងន

ទីប្រឹក្សា៖

១ – សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ

២ – សម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា ល្វី-ឯម

៣ – ព្រះពោធិវង្ស ហួត-តាត (វជិរប្បញ្ញោ) វត្ត ឧណ្ណាលោម

៤ – ព្រះមហាព្រហ្មមុនី ទ-អ៊ូ (ថិតវីរិយោ) " ស្វាយពពែ

៥ – ព្រះឧបាលិវង្ស សូរ-ហាយ (សុវណ្ណសរេ) " ឧណ្ណាលោម

៦ – ព្រះធម្មត្រៃលោកាចារ្យ ក-គោ (ថិតសីលោ) " បទុមវតី

៧ – ព្រះពុទ្ធវង្ស កៅ-ស៊ឹម (សិរីបញ្ញោ) " លង្កា

៨ – ព្រះវិន័យសង្វរ រាជ-គឹង (សុវណ្ណកេសរេ) " សារាវ័ន

៩ – ព្រះកិត្តិ ប៉ាង. ខាត់ (វីរិយបណ្ឌិតោ) " ឧណ្ណាលោម

១០ – ព្រះគ្រូសង្ឃសត្ថា ប៉ុណ្ណ-សុភាជ (ធម្មាភោ) " "

## សមាសភាពនៃគណកម្មាធិការនាយក

ដែលមហាសន្និបាត ទី ៥ បានជ្រើសតាំងពីថ្ងៃទី ១៦ មករ ១៩៥៧

សំរាប់ឆ្នាំ ១៩៥៧

ប្រធាន លោក សម - ញាណ

អនុប្រធាន ទី ១ ” ប៉ាយ - លុត

” ២ ” ទេស - យ៉ន់

” ៣ ” ម៉ី-នរសីហ៍

អគ្គលេខាធិការ ” ម៉ែន - ទន់

លេខាធិការទី ១ ” ទា - គិមឡុង

” ២ ” នូ - ឯម

អគ្គហេរញ្ញិក ” រស់ - ហែម

ហេរញ្ញិក ទី ១ ” បេ - យាន

,, ២ ” អ៊ឹង - គិមងន

ស្នងការ: លោកស្រី អ៊ឹង - គិមងន, លោកស្រី ប៉ាយ - លុត, លោកស្រី គង់-សរ, លោក មាស - ម៉ន, លោក ឡឹក - ឡាញ់, លោក ទា - ផាវលី, លោក ម៉ី - នាង ។

## ទីប្រឹក្សា៖

១– សម្តេចព្រះមហាសុមេធាធិបតី ជួន - ណាតសង្ឃនាយកគណៈមហានិកាយ

២– សម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា ល្វី - ឯម

៣– ព្រះពោធិវង្ស ហួត - តាត (វជិរប្បញ្ញោ) វត្ត ឧណ្ណាលោម

៤– ព្រះមហាព្រហ្មមុនី ទេ - ឆ៊ូ (ថិតវីរយោ) ” ស្វាយពពែ

៥– ព្រះឧបាលិវង្ស ស្វរ - ហាយ (សុវណ្ណសរោ) ” ឧណ្ណាលោម

៦– ព្រះធម្មត្រៃលោកាចារ្យ ក - គោ (ថិតសីលោ) ” បទុមវតី

៧– ព្រះពុទ្ធវង្ស កៅ - ស៊ឹម (សីរីបញ្ញោ) ” លង្កា

៨– ព្រះគ្រូសង្ឃសត្ថាប៉ុណ្ណ - សម្ភាជ (ធម្មាភោ) ” ឧណ្ណាលោម

៩– ព្រះមហា ប៉ាង - ខាត់ (វីរិយបណ្ឌិតោ) ” –ដ–

# សមាសភាពនៃគណកម្មាធិការនាយក

ដែលមហាសន្និបាតទី ៦ បានជ្រើសតាំងពីថ្ងៃទី ៧ មករា គ.ស. ១៩៥៨

សំរាប់ឆ្នាំ ១៩៥២

| | | |
|---|---|---|
| ប្រធាន | លោក | សម - ញាណ |
| អនុប្រធានទី ១ | " | ពាយ - លុត |
| – ដ – ទី ២ | " | ម៉ុ - នរស៊ីហ៍ |
| អគ្គលេខាធិការ | " | អេង - មាស |
| លេខាធិការ | " | យុង - យ៉ា |
| អគ្គហេរញ្ញិក | " | រស់ - ហែម |
| ហេរញ្ញិក | " | ប៉េ - យាន |
| ស្នងការ | " | ចា - ជាវលី, អ៊ឹង - គីមង៉ន, ជា - ផុង, ម៉ែន - ចន់, នូ - ឯម, លោកស្រី ពាយ - លុត, គង់-សរ |

និងលោកស្រី អ៊ឹង - គីមង៉ន

## ទីប្រឹក្សា៖

១ – សម្តេចព្រះមហាសុមេធាធិបតី ជួន - ណាត សង្ឃនាយកគណៈមហានិកាយ

| | | | | |
|---|---|---|---|---|
| ២ – ព្រះពោធិវង្ស | ហួត - តាត | (វជិរបញ្ញោ) | វត្ត | ឧណ្ណាលោម |
| ៣ – ព្រះមហាព្រហ្មមុនី | ខូ - អ៊ូ | (ចិតវីរិយោ) | " | ស្វាយពពែ |
| ៤ – ព្រះធម្មត្រៃលោកាចារ្យ | ក-គោ | (ចិតសីលោ) | " | បទុមវតី |
| ៥ – ព្រះពុទ្ធវង្ស | កៅ - សឹម | (សិរីបញ្ញោ) | " | លង្កា |
| ៦ – ព្រះឧបាលិវង្ស | សូរ - ហាយ | (សុវណ្ណសរោ) | " | ឧណ្ណាលោម |
| ៧ – ព្រះឥន្ទមុនី | កែវ - ពាន់ | (សុវណ្ណត្ថេរោ) | " | – ដ – |
| ៨ – ព្រះគ្រូធម្មបណ្ឌិត | គង់ - ស៊ុម | (ធម្មត្ថេរោ) | " | – ដ – |
| ៩ – ព្រះកិត្តុ | ប៉ាង - ខាត់ | (វីរិយបណ្ឌិតោ) | " | – ដ – |

# សមាសភាពនៃគណៈកម្មាធិការនាយក

ដែលមហាសន្និបាត ទី ៧ បានជ្រើសតាំងពីថ្ងៃទី ២៤ មករា គ.ស. ១៩៥៩

សំរាប់ឆ្នាំ ១៩៥៩

| | | |
|---|---|---|
| ប្រធាន | លោក | ប៉ុយ-លុត |
| អនុប្រធាន ទី ១ | ” | សម-ញាណ |
| ” ២ | ” | ម៉ី-នរសីហ៍ |
| ” ៣ | លោកស្រី | ដោក-ស៊ីដេត |
| អគ្គលេខាធិការ | លោក | សម-ថាំង |
| លេខាធិការ | ” | គង់-សរ |
| អគ្គហេរញ្ញិក | ” | រស់-ហែម |
| ហេរញ្ញិក ទី ១ | ” | បេ-យាន |
| ” ទី ២ | ” | អ៊ឹង-គីមង៉ន |

ស្នងការ លោក ស្រីគង់-សរ, លោក ស្រី ប៉ុយ-លុត, លោកស្រីអ៊ឹង-គីមង៉ន, លោកស្រីសម-ញាណ, លោក នូ-ឯម, លោក ឈឹម-ស៊ុំ, លោក ទា-ដាវលី, លោក ទា-គឹមឡុង ។

## ទីប្រឹក្សាៈ

១– សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ

២– ព្រះពោធិវង្ស ហួត-តាត (វជីរប្បញ្ញោ) វត្តឧណ្ណាលោម

៣– ព្រះធម្មលិខិត ម៉ុង-សែស (ចៅអធិការ) ” មហាមន្ត្រី

៤– ព្រះឃោសធម្ម កៅ-ស៊ុម (សិរិបញ្ញោ) ” លង្កា

៥– ព្រះឧបាលិវង្ស សួរ-ហាយ (សុវណ្ណសរោ) ” ឧណ្ណាលោម

៦ – លោកអ្នកឧកញ៉ាអតីតពជតេជះ : គាន់-មៅ

៧ – អ្នកឧកញ៉ា សុគន្ធប្រីជា មុី-នាង

៨ – លោក . . . . . . ឃោក-ម៉ែន

# សមាសភាពនៃគណៈកម្មាធិការនាយក

ដែលមហាសន្និបាតទី ៨ បានជ្រើសតាំងពីថ្ងៃទី ២៣ មករា គ.ស. ១៩៦០

សំរាប់ឆ្នាំ ១៩៦០

ប្រធាន លោក ព៉យ-លុត

អនុប្រធានទី ១ „ គាន់-មៅ អតីតពជតេជះ

„ ២ លោកស្រី ដោក-ស៊ីដេត

„ ៣ លោក គង់-សរ

អគ្គលេខាធិការ លោក មែរ-ប៉ាន់

លេខាធិការ „ នូ-ឯម

អគ្គហេរញ្ញិក „ រស់-ហែម

ហេរញ្ញិកទី ១ „ បេ-យាន

„ ២ „ អ៉ឹង-គឹមង៉ន

ស្នងកា : លោក សោម-នៅ, លោក ឆា-ដារលី, លោក ប៊ុណ-ថាន់, លោក ឃោក ម៉ែន, លោកស្រី ព៉យ-លុត, លោកស្រី អ៉ឹង-គិមង៉ន, លោកស្រី គង់-សរ ។

ទីប្រឹក្សា៖

១– សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ

២– ព្រះពោធិវង្ស ហួត-តាត (ដើរប្បញ្ញោ) វត្ត ឧណ្ណាលោម

៣– ព្រះធម្មលិខិត ម៉ុង-សែស ចៅអធិការ „ មហាមន្ត្រី

៤– ព្រះឃោសធម្ម កៅ-ស៊ុម ចៅអធិការ „ លង្កា

៥– ព្រះឧបាលិវង្ស សូរ-ហាយ (សុវណ្ណសារោ „ ឧណ្ណាលោម

# របៀបការគ្រប់គ្រងគណៈសង្ឃ

## ក្នុង
## ប្រទេសកម្ពុជា

ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា មានការគ្រប់គ្រងគណៈសង្ឃពុទ្ធសាសនិក ដោយផ្លាស់ប្រែរបៀបសម្រួលការតាមលំដាប់កាល ដូចខាងក្រោមនេះ៖

១– កាលពីក្នុងរជ្ជកាលព្រេងនាយ វត្តអារាមជាលំនៅរបស់សង្ឃ មានចំនួនតិចនៅឆ្ងាយ ៗ ពីគ្នាដល់ ១០ គីឡូម៉ែត្រក៏មានក្នុងខេត្រទីមួយ ៗ មានមហាថេរជាព្រះឧបជ្ឈាយ៍ក៏មិនច្រើនប៉ុន្មាន ការគ្រប់គ្រងគណៈសង្ឃរាល់ខេត្រ ជាភារៈលើព្រះឧបជ្ឈាយ៍មួយរូប ៗ ដែលមានវត្តតិចខ្លះច្រើនខ្លះជាចំណុះ ៗ ព្រះឧបជ្ឈាយ៍ទាំងនោះសុទ្ធតែឋិតនៅក្រោមអំណាចនៃសម្ដេចព្រះសង្ឃរាជមួយព្រះអង្គជាប្រមុខសង្ឃ ដែលគង់នៅវត្តក្នុងព្រះរាជធានី ដោយមានព្រះរាជាគណៈ ឋានានុក្រម ឯក-ទោ-ត្រី-ចត្វា ទាំង៤ថ្នាក់នេះជាសហការី សម្រេចសង្ឃកិច្ចគ្រប់យ៉ាងក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ។

២– លុះចំណេរកាលតមក វត្តអារាមកាន់តែកើតមានច្រើនឡើងជាងពីមុន ព្រះឧបជ្ឈាយ៍មួយ ៗ ពុំអាចគ្រប់គ្រងគណៈសង្ឃឲ្យគ្រប់គ្រាន់បាន ទើបសម្ដេចព្រះសង្ឃរាជជាប្រមុខសង្ឃ បានប្រឹក្សាជាមួយនឹងព្រះរាជាគណៈ ឋានានុក្រម, មានការយល់ស្របគ្នាស្រេចហើយ, ក៏បានថ្វាយព្រះពរព្រះមហាក្សត្រិយ៍សូមព្រះរាជទានព្រះបរមរាជានុញ្ញាតតាំងព្រះមហាថេរទាំងឡាយនៅខេត្រក្រៅ ដែលមានសមត្ថភាពគួរដល់កិច្ចការ ឲ្យធ្វើជាមេគណ ក្នុងខេត្រមួយ ៗ ឲ្យមានមេគណមួយរូប ៗ មានសមណស័ក្តិទីឋានានុក្រម មានឋានន្តរគឺងារផ្សេង ៗ គ្នា ឲ្យគ្រប់គ្រងការត្រួតត្រាលើគណៈសង្ឃក្នុងខេត្ររៀងខ្លួន ៗ ព្រះរាជាគណៈទាំង៤ថ្នាក់ ឯក-ទោ-ត្រី-ចត្វា ត្រូវទទួលភារៈត្រួតត្រាសង្ឃកិច្ចក្នុងខេត្រទីមួយ ៗ តាមដោយសម្ដេចព្រះសង្ឃរាជទ្រង់ប្រទានខេត្រធំឬខេត្រតូច តាមថ្នាក់សមណស័ក្តិ ព្រះរាជាគណៈទាំងនោះហៅថា « កំណាន់ខេត្រ » ប្រែថា « អ្នកកាន់ការត្រួតត្រាលើលោកមេគណក្នុងខេត្ររបស់ខ្លួន » ។ ក្នុងហេមន្តរដូវរៀងរាល់ឆ្នាំ ចាប់ដើមតាំងពីថ្ងៃ១រោចខែកត្តិកដល់ថ្ងៃ១៥កើតខែផល្គុន, នៅថ្ងៃខែណាមួយក៏បាន. លោកមេគណគ្រប់ខេត្រ ត្រូវចូលមកជួបនឹងលោកព្រះរាជាគណៈជាកំណាន់ខេត្ររបស់ខ្លួន, លោកកំណាន់ខេត្រត្រូវនាំចូលក្រាបថ្វាយបង្គំគាល់សម្ដេចព្រះសង្ឃរាជ ដើម្បីទទួលឱវាទផង ដើម្បីក្រាបបង្គំទូលស្នើអំពីធម៌វិន័យនឹងផ្លូវប្រតិបត្តិផ្សេង ៗ ដែលគួរទូលស្នើផង ការដែលលោកមេគណរាល់ខេត្រចូលមកក្នុង១ឆ្នាំម្ដងនេះហៅថា « ឡើងគណ » ។

៣– លុះចំណេរកាលតមកទៀត វត្តអារាមកាន់តែកើតមានច្រើនឡើង ព្រោះចំនួនកុលបុត្រធ្វើបព្វជ្ជានៅរបស់គ្រហស្ថពុទ្ធសាសនិកចេះតែមានច្រើនឡើងឆ្ងាយ ៗ ពីវត្តចាស់ ការគ្រប់គ្រងគណសង្ឃក៏ត្រូវផ្លាស់របៀបផ្សេងពីរបៀបមុន ឲ្យសមតាមដំណើរការណ៍គ្រប់គ្រងប្រទេសខាងអាណាចក្រ ដែលចាត់របៀបឲ្យមានខេត្រ, ស្រុក, តំបន់ ឲ្យមានចៅហ្វាយខេត្រ, ចៅហ្វាយស្រុក, មេតំបន់ ។

ក្នុងខេត្រមួយ ៗ ត្រូវឲ្យមាន មេគណ មួយរូប ៗ ក្នុងស្រុកមួយ ៗ ត្រូវឲ្យមានអនុគណមួយរូប ៗ តំបន់ខ្លះមានអនុគណមួយរូបដែរ តាមសេចក្ដីសុំរបស់ចៅហ្វាយខេត្រ អនុគណនេះតាំងជាពិសេស តាមដំណើរការណ៍គ្រប់គ្រងគណៈសង្ឃ ប៉ុន្តែអនុគណប្រភេទនេះមានតិចដែរទេ ។

គណៈសង្ឃសម្រាប់មេគណមាន ៥ រូបគឺ មេគណ ១រូប, បាឡាត់គណ ១ រូប, វិន័យធរគណ ១ រូប, សមុហ៍គណ ១ រូប, លេខាធិការគណ ១ រូប ។ គណៈសង្ឃសម្រាប់អនុគណមាន ៤ រូបគឺ អនុគណ ១ រូប, វិន័យធរអនុគណ ១ រូប, សមុហ៍អនុគណ ១ រូប, អនុលេខាធិការអនុគណ ១ រូប ។

ការតាំងសមណស័ក្តិទីមេគណ, មុនដំបូង, ត្រូវព្រះសង្ឃនាយកតាំង ជាឋានានុក្រមទីព្រះគ្រូដោយរដ្ឋមន្ត្រីក្រសួងធម្មការបានចុះហត្ថលេខាបោះត្រាពីខាងត្បូងលើសន្លឹកសញ្ញាបត្រផង លុះតពីនោះយូរបន្តិចមកព្រះមហាក្សត្រិយ៍ទ្រង់ព្រះមេត្តាប្រោសប្រទានព្រះរាជក្រឹត្យតាំងឲ្យឡើងជាព្រះរាជាគណៈ ទីមេគណដដែលតាមសេចក្ដីក្រាបបង្គំទូលសូមនៃរដ្ឋមន្ត្រីក្រសួងធម្មការ ។

អនុគណមានសមណស័ក្តិជាឋានានុក្រមទីព្រះគ្រូ ។ ឯសមណស័ក្តិទីបាឡាត់, វិន័យធរ សមុហ៍, លេខាធិការ នឹង អនុលេខាធិការ ក៏សុទ្ធតែមានសមណស័ក្តិទីឋានានុក្រមដែរ ។ មន្ត្រីសង្ឃខាងលើនេះ នឹងចៅអធិការវត្ត គ្រូសូត្រស្តាំ, គ្រូសូត្រឆ្វេង គ្រប់វត្តទាំងអស់ក្នុងព្រះរាជាណាចក្រ លើកលែងតែសមណ-ស័ក្តិទីរាជាគណៈចេញ សុទ្ធតែត្រូវព្រះសង្ឃនាយកតាំង ដោយរដ្ឋមន្ត្រីក្រសួងធម្មការចុះហត្ថលេខាបោះត្រាពីខាងត្បូងលើសន្លឹកសញ្ញាបត្រផងជាដរាប ដើម្បីឲ្យព្រះរាជរដ្ឋាភិបាលទទួលស្គាល់តាមផ្លូវការ ដែលមានការគ្រប់គ្រងព្រះពុទ្ធសាសនាទាក់ទងគ្នា ព្រោះប្រទេសប្រៀបដូចតួរាជរថ្យរទេះបន្ទុក ត្រូវមានអាណាចក្រជាកង់ម្ខាង ពុទ្ធចក្រជាកង់ម្ខាង អាណាចក្រជាកង់ខាងអំណាច ពុទ្ធចក្រជាកង់ខាងសីលធម៌ ត្រូវប្រតិបត្តិការឲ្យកង់ទាំង ២ នេះវិលស្មើគ្នា ទើបរាជរថ្យរទេះបន្ទុកគឺប្រទេសកម្ពុជា អាចលឿនទៅរកសុខសន្តិភាពនឹងវឌ្ឍនភាពបាន ។

ក្នុងសម័យបច្ចុប្បន្ននេះ កិច្ចការសង្ឃគ្រប់ខេត្រ-ស្រុក មានកាន់តែច្រើនឡើង ព្រោះការសិក្សាខាងព្រះពុទ្ធសាសនាកាន់តែល្អលើសចំរើនជាងសម័យពីដើម ព្រះសង្ឃនាយកបានសុំបង្កើតឲ្យមានកិច្ចសហការី សម្រាប់មេគណខេត្តនិងអនុគណ ក៏បានតាំងសមណស័ក្តិ ព្រះគ្រូមានឋានន្តរផ្សេងៗគ្នា ជាសហការីជួយចាត់ការមន្ត្រីសង្ឃខេត្តនិងស្រុកឡើងទៀត តាមសេចក្តីសុំតាមផ្លូវការរបស់មេគណខេត្តនិងអនុគណ ។

ចំនួនវត្តព្រះសង្ឃក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុង ព.ស. ២៥០២ គ.ស. ១៩៥៩ ខាងគណៈមហានិកាយ មានវត្ត ១៧២៥ ខាងគណៈធម្មយុត្តិកនិកាយ មានវត្ត ១០៦ រួមវត្តទាំង ២ និកាយមាន ១៨៣១ ។ វត្តទាំងឡាយដែលទើបកសាងថ្មី ពុំទាន់ចុះក្នុងបញ្ជី មិនរាប់បញ្ចូលក្នុងចំនួនខាងលើនេះទេ ។

## ព្រះសង្ឃនាយកទាំង ២ គណៈ

១ – ព្រះសង្ឃនាយកខាងគណៈមហានិកាយ មានឋានន្តរជា សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយ ។

២ – ព្រះសង្ឃនាយកខាងគណៈធម្មយុត្តិកនិកាយ មានឋានន្តរជា សម្តេចព្រះសុធម្មាធិបតី សង្ឃនាយក គណៈធម្មយុត្តិកនិកាយ ។

ព្រះសង្ឃនាយកទាំង ២ អង្គនេះ មាននាទីគ្រប់គ្រងត្រួតត្រាសង្ឃកិច្ចតាមគណៈដោយខ្លួនពីគ្នា ពុំបានរួបរួមជាមួយគ្នាទេ ប៉ុន្តែកាលបើមានការត្រូវចេញព្រះសង្ឃប្រកាសម្ពុទ្ធព្រះសង្ឃបញ្ញត្តិជាសាធារណៈ មិនចំពោះគណៈនិកាយទេ ត្រូវរួបរួមជាមួយគ្នា ។

## ព្រះរាជាគណៈក្នុងតំណែង

ព្រះរាជាគណៈក្នុងតំណែងមាន ៤ ថ្នាក់គឺ ឯក-ទោ-ត្រី-ចត្វា ។ ថ្នាក់ឯកមាន ៥ , ថ្នាក់ទោមាន ៩ , ថ្នាក់ត្រីមាន ១០ , ថ្នាក់ចត្វាមាន ៣២ រួមទាំង ៤ ថ្នាក់ជា ៥៦ ។ បណ្តាព្រះរាជាគណៈទាំង ៥៦ នេះ , ខាងគណៈមហានិកាយមាន ៣៥ , ខាងគណៈធម្មយុត្តិកនិកាយមាន ២១ មានឋានន្តរគឺងារផ្សេងៗគ្នា ដូចខាងក្រោមនេះ

### ខាងគណៈមហានិកាយ

ព្រះរាជាគណៈថ្នាក់ឯកមាន ៣ គឺ

១ – ព្រះធម្មលិខិត

២ – ព្រះពោធិវង្ស

៣ – ព្រះវនរ័ត

ព្រះរាជាគណៈថ្នាក់ទោមាន ៦ គឺ

១ – ព្រះមហាវិមលធម្ម

២ – ព្រះពុទ្ធឃោសាចារ្យ

៣ – ព្រះធម្មឃោសាចារ្យ

៤ – ព្រះឃោសធម្ម

៥ – ព្រះសាសនមុនី

៦ – ព្រះមុនីកោសល

ព្រះរាជាគណៈថ្នាក់ត្រីមាន ៦ គឺ

១ – ព្រះសិរីសម្មតិវង្ស

២ – ព្រះពុទ្ធវង្ស

៣ – ព្រះសាក្យវង្ស

៤ – ព្រះឧបាលិវង្ស

៥ – ព្រះញាណវង្ស

៦ – ព្រះសុមេធវង្ស

ព្រះរាជាគណៈថ្នាក់ចត្វាមាន២០ គឺ

១ – ព្រះធម្មវិបស្សនា

២ – ព្រះសមាធិធម្ម

៣ – ព្រះញាណកោសល

៤ – ព្រះសិរីសត្ថាមុនី

៥ – ព្រះសិរីសុទ្ធ

៦ – ព្រះធម្មវង្ស

៧– ព្រះញាណសំវរ

៨– ព្រះវិន័យសំវរ

៩– ព្រះឥន្ទមុនី

១០– ព្រះទេពមុនី

១១– ព្រះវិន័យមុនី

១២– ព្រះទេពសត្ថា

១៣ – ព្រះសីលសំវរ

១៤– ព្រះគម្ភីរត្ថេរ

១៥ - ព្រះអរិយមគ្គញាណ

១៦– ព្រះវិកខ្ញាណ

១៧– ព្រះបវរសត្ថា

១៨– ព្រះញាណវិសុទ្ធិវង្ស

១៩ – ព្រះធម្មវិសុទ្ធិវង្ស

២០ ព្រះបិដកធម្ម

## ខាងគណៈធម្មយុត្តិកនិកាយ

## ព្រះរាជាគណៈថ្នាក់ឯកមាន២ គឺ

១– ព្រះមង្គលទេពាចារ្យ

២– ព្រះពុទ្ធាចារ្យ

## ព្រះរាជាគណៈថ្នាក់ទោមាន ៣ គឺ

១– ព្រះមហាព្រហ្មមុនី

២– ព្រះធម្មឧត្តម

៣– ព្រះអរិយកស្សប

## ព្រះរាជាគណៈថ្នាក់ត្រីមាន៤គឺ

១ – ព្រះអរិយវង្ស

២ – ព្រះធម្មកវីវង្ស

៣ – ព្រះញាណរង្សី

៤ – ព្រះមហាវីរវង្សាចារ្យ

## ព្រះរាជាគណៈថ្នាក់បត្វាមាន១២គឺ

១ – ព្រះបទុមវង្សា

២ – ព្រះធម្មមុនី

៣ – ព្រះវជិរមេធា

៤ ព្រះអរិយមុនី

៥ – ព្រះទេពមោលី

៦ – ព្រះធម្មគ្គេរ

៧ - ព្រះអមរាភិរក្ខិត

៨ – ព្រះមហាភជធម្ម

៩ – ព្រះរតនមុនី

១០ – ព្រះធម្មត្រ័យលោកាចារ្យ

១១– ព្រះធម្មវរោត្តម

១២ - ព្រះញាណវិរិយ

ព្រះសង្ឃនាយកទាំង ២ ព្រះអង្គ និងព្រះរាជាគណៈក្នុងតំណែងទាំង ៤៦ អង្គនេះ សុទ្ធតែព្រះមហាក្សត្រិយ៍ទ្រង់ប្រោសព្រះរាជទានព្រះក្រឹត្យតាំង ។

## ឋានន្តរមន្ត្រីសង្ឃទីមេគណៈ

គ្រប់ខេត្តទាំង ១៤

១ – ខេត្តបាត់ដំបង ព្រះសង្ឃកិច្ចកោសល

| | | | |
|---|---|---|---|
| ២ – | ខេត្ត | កណ្ដាល | ព្រះវិមលវេទី |
| ៣ – | ,, | កំពង់ចាម | ព្រះនាគមុនី |
| ៤ – | ,, | កំពត | ព្រះផលធីរាសី |
| ៥ – | ,, | ព្រៃវែង | ព្រះមុនីរក្ខិតវង្សា |
| ៦ – | ,, | កំពង់ឆ្នាំង | ព្រះធម្មវង្សាធិបតី |
| ៧ – | ,, | តាកែវ | ព្រះមង្គលទិព្វលោកវង្ស |
| ៨ – | ,, | ស្វាយរៀង | ព្រះវង្សាបតីធម្មធារ |
| ៩ – | ,, | កំពង់ធំ | ព្រះសត្ថាបារមី |
| ១០ – | ,, | សៀមរាប | ព្រះសុមង្គលសីលាចារ្យ |
| ១១ – | ,; | ក្រចេះ | ព្រះសុគន្ធសីលសារ |
| ១២ – | ,, | កំពង់ស្ពឺ | ព្រះមុនីសត្ថាចារ្យកោសល |
| ១៣ – | ,, | ពោធិ៍សាត់ | ព្រះពោធិវង្សាវិមល |
| ១៤ – | ,, | ស្ទឹងត្រែង | ព្រះធម្មកោសលហ៊ុកខាំ |

## ឋានន្តរមន្ត្រីសង្ឃទីបាឡាត់គណ

គ្រប់ខេត្តទាំង ១៤

| | | | | |
|---|---|---|---|---|
| ១ – | ខេត្ត | បាត់ដំបង | ព្រះបាឡាត់ | វិមលមុនី |
| ២ – | ,, | កណ្ដាល | ,, | វេទីវង្សា |
| ៣ – | ,, | កំពង់ចាម | ,, | នាគសត្ថា |
| ៤ – | ,, | កំពត | ,, | សាគរវង្ស |
| ៥ – | ,, | ព្រៃវែង. | ,, | ព្រហ្មបញ្ញា |
| ៦ – | ,, | កំពង់ឆ្នាំង | ,, | សុធម្មចារី |
| ៧ – | ,; | តាកែវ | ,, | ទិព្វលោកមុនី |
| ៨ – | ,, | ស្វាយរៀង | ,, | គម្ពីរធម្មសត្ថា |

| | | | |
|---|---|---|---|
| ៩ – | ខេត្រ កំពង់ធំ | ព្រះបាឡាត់ | បារមីធម្មបាល |
| ១០ – | ,, សៀមរាប | ,, | វិសាលបញ្ញា |
| ១១ – | ,, ក្រចេះ | ,, | វិនយមេធា |
| ១២ – | ,, កំពង់ស្ពឺ | ,, | សត្ថាភិរក្ខិត |
| ១៣ – | ,, ពោធិ៍សាត់ | ,, | វិចិត្តព្រហ្មធម៌ |
| ១៤ – | ,, ស្ទឹងត្រែង | ,, | បវរវិទូ |

## ១)ខេត្របាត់ដំបងមានអនុគណ ១១

| | | | |
|---|---|---|---|
| ១ – | ស្រុកបាត់ដំបង | ព្រះគ្រូ | សិរីសត្ថា |
| ២ – | ស្រុកសង្កែ | ,, | បញ្ញាវង្ស |
| ៣ – | ស្រុកមោងឫស្សី | ,, | ធម្មវង្ស |
| ៤ – | ស្រុកមង្គលបុរី | ,, | សិរីមង្គល |
| ៥ – | ស្រុកសិរីសោភ័ណ | ,, | សោភ័ណវិមល |
| ៦ – | ស្រុកទឹកជោរ | ,, | កោសលមេធី |
| ៧ – | ស្រុកប៉ៃលិន | ,, | វជិរបញ្ញា |
| ៨ – | តំបន់ល្វា | ,, | សំវរសត្ថា |
| ៩ – | តំបន់ស្វាយចេក | ,, | បញ្ញារក្ខិត |
| ១០ – | ស្រុកភ្នំស្រុក | ,, | បរិត្តមេធា |
| ១១ – | ស្រុកបន្ទាយឆ្មារ | ,, | ធម្មានុចារី |

## ២)ខេត្រកណ្ដាលមានអនុគណ ១០

| | | | |
|---|---|---|---|
| ១ – | ស្រុកភ្នំពេញ | ព្រះគ្រូ | ទុជ័យវង្ស |
| ២ – | ស្រុកពញាឮ | ,, | ចរិយាកោសល |
| ៣ – | ស្រុកខ្សាច់កណ្ដាល | ,, | ញាណវិមល |
| ៤ – | ស្រុកមុខកំពូល | ,, | មង្គលវង្ស |

៥– ស្រុកកៀនស្វាយ ព្រះគ្រូ វិសុទ្ធិវង្សា
៦– ស្រុកល្វាឯម – បញ្ញាសិរី
៧– ស្រុកកណ្ដាលស្ទឹង – វិន័យវេទី
៨– ស្រុកលើកដែក – មុនីកោវិទ
៩– ស្រុកស្អាង – វិជិតមេធា
១០– ស្រុកកោះធំ – បញ្ញានុរក្ខិត

## ៣) ខេត្តកំពង់ចាមមានអនុគណ ១១

១– ស្រុកកំពង់សៀម ព្រះគ្រូ សំវរមុនី
២– ស្រុកព្រៃឈរ – វជិរវិទូ
៣– ស្រុកជើងព្រៃ – សង្ឃរក្ខិតញ្ញូ
៤– ស្រុកកោះសូទិន – វិទូទីបបាល
៥– ស្រុកត្បូងឃ្មុំ – មធុរធម្មវង្ស
៦– ស្រុកក្រូចឆ្មារ – សិរីវិសាល
៧– ស្រុកមេមត់ – វិសុទ្ធធម្មបាល
៨– ស្រុកស្ទឹងត្រង់ – វិសាលធម្មទស្សី
៩– ស្រុកស្រីសន្ធរ – សិរីវិជ្ជា
១០– ស្រុកកងមាស – បញ្ញារង្សី
១១– ស្រុកចំការលើ – សិរីធម្មរក្ខិត

## ៤) ខេត្តកំពតមានអនុគណ ៧

១– ស្រុកកំពត ព្រះគ្រូ សាគរសោភ័ណ
២– ស្រុកបន្ទាយមាស – សុវណ្ណរង្សី
៣– ស្រុកកំពង់ត្រាច – វិសុទ្ធគរី
៤– ស្រុកកំពង់សោម – សិរីធម្មធាតា

៥– ស្រុកឈូក ព្រះគ្រូ បទុមគាមវត្ត

៦– ស្រុកកោះកុង – ទីបវត្តសត្ថា

៧– ស្រុកព្រៃនប់ – សត្ថាមុនីវគុណ

## ៥) ខេត្តព្រៃវែងមានអនុគណ ៧

១– ស្រុកព្រៃវែង ព្រះគ្រូ ទីឃវ័នមេធា

២– ស្រុកកំចាយមារ „ មាភនុវិជ័យ

៣– ស្រុកពារាំង „ សំវរវិន័យ

៤– ស្រុកស៊ីធរកណ្ដាល „ វិជ័យមុនី

៥– ស្រុកបាភ្នំ „ មេត្តាធម្មធរ

៦– ស្រុកកំពង់ត្របែក „ បវរវេទី

៧– ស្រុកកញ្ជ្រៀច „ មុនីមង្គល

## ៦) ខេត្តកំពង់ឆ្នាំងមានអនុគណ ៥

១– ស្រុករលាប្អៀរ ព្រះគ្រូ ធម្មានុវត្ត

២– ស្រុកបរិបូណ៌ „ អភិរ័តសីលធម៌

៣– ស្រុកកំពង់លែង „ សាក្យបុត្តសំវរ

៤– ស្រុកកំពង់ត្រឡាច „ ធម្មធរជិនបុត្ត

៥– ស្រុកទឹកផុស „ វិសុទ្ធសីលគុណ

## ៧) ខេត្តតាកែវមានអនុគណ ៧

១– ស្រុកត្រាំង ព្រះគ្រូ ធម្មវិមល

២– ស្រុកគិរីវង្ស „ មង្គលកេសរ

៣– ស្រុកកោះអណ្ដែត „ រតនប្បវរ

៤– ស្រុកបាទី „ ធម្មសារមុនី

៥– ស្រុកសំពេន „ ទុត្តិយមេធា

| | | |
|---|---|---|
| ៦- ស្រុកព្រែកប្រាស | ព្រះគ្រូ | វិជ្ជាវេទី |
| ៧- ស្រុកត្រាំកក់ | ,, | ធីរវង្សាចារ្យ |

## ៨) ខែត្រស្វាយរៀងមានអនុគណ ៤

| | | |
|---|---|---|
| ១- ស្រុកស្វាយរៀង | ព្រះគ្រូ | ធម្មបាលវង្សា |
| ២- ស្រុករំដួល | ,, | នាថាភិរក្ខិត |
| ៣- ស្រុកស្វាយទាប | ,, | វិនយកោវិទ |
| ៤- ស្រុករមាសហែក | ,, | បរិត្តវិទូ |

## ៩) ខែត្រកំពង់ធំមានអនុគណ ៨

| | | |
|---|---|---|
| ១- ស្រុកកំពង់ស្វាយ | ព្រះគ្រូ | វីរិយធម្មគុត្ត |
| ២- ស្រុកសណ្ដាន់ | ,, | វិសុទ្ធសត្ថា |
| ៣- ស្រុករវៀង | ,, | សោភ័ណបញ្ញា |
| ៤- ស្រុកបារាយណ៍ | ,, | ចរិយានុរក្ខ |
| ៥- ស្រុកស្ទោង | ,, | បរិត្តកោសល |
| ៦- ស្រុកសន្ទុក | ,, | និម្មលធម្មលក្ខណ៍ |
| ៧- ស្រុកជាំក្សាន្ត | ,, | សារញាណសិទ្ធិសក្តិ |
| ៨- ស្រុកឆែប | ,, | រដ្ឋានុរក្ខកោសល |

## ១០) ខែត្រសៀមរាបមានអនុគណ ៦

| | | |
|---|---|---|
| ១- ស្រុកសៀមរាប | ព្រះគ្រូ | បាសាទវង្សី |
| ២- ស្រុកពួក | ,, | សិរីវេទី |
| ៣ ស្រុកក្រឡាញ់ | ,, | សង្ឃមុនី |
| ៤- ស្រុកសូទ្រនិគម | ,, | គម្ភីរធម្មាចារ្យ |
| ៥- ស្រុកជីក្រែង | ,, | សារធម្មបាល |
| ៦- ស្រុកសំរោងចុងកាល់ | ,, | វិសាលបញ្ញា |

## ១១) ខេត្តក្រចេះមានអនុគណ ៤

១- ស្រុកក្រចេះ ព្រះគ្រូ សីលគន្ធប្បជោត

២- ស្រុកសម្បូណ៌ " វិសោធបញ្ញា

៣- ស្រុកស្នួល " វិសុទ្ធមេធា

៤- ស្រុកឆ្លូង " គង្គាឧទ័យ.សីលធម៌

## ១២) ខេត្តកំពង់ស្ពឺមានអនុគណ ៥

១- ស្រុកសំរោងទង ព្រះគ្រូ វិន័យភទី

២- ស្រុកគងពិសី " មុនីវង្ស

៣- ស្រុកថ្ពង " អរិយសត្ថា

៤- ស្រុកឧដុង្គ " បញ្ញាឧត្តម

៥- ស្រុកភ្នំស្រួច " ព្រហ្មគិរីធម្មបាល

## ១៣) ខេត្តពោធិ៍សាត់មានអនុគណ ៣

១ ស្រុកបាកាន ព្រះគ្រូ ឧត្តមសត្ថា

២- ស្រុកភ្នំក្រវាញ — មេត្តាវិហារី

៣- ស្រុកក្រគរ — សុធីរញ្ញាណ

## ១៤) ខេត្តស្ទឹងត្រែងមានអនុគណ ៣

១- ស្រុកស្ទឹងត្រែង ព្រះគ្រូ ធម្មាភិរ័ត

២- ស្រុកវិនសៃ — សុគន្ធបរិយា

៣- ស្រុកថ:លាបរិវ័ត — វិនយានុរ័ក្ខ

ខាងគណ:ធម្មយុត្តិកនិកាយ មិនមានមេគណនឹងអនុគណទេ ព្រោះពល់ខេត្ត, គណ:នេះ មានវត្តតិច, នឹងតាំងមេគណ - អនុគណពុំទាន់កើតនៅឡើយ ។

ក្នុងសម័យបច្ចុប្បន្ននេះ ព្រះរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមបានបង្កើតឲ្យមានខេត្តថ្មី ២ ថែមឡើងទៀតគឺ

វត្តកោះកុង ១ វត្តរតនគិរី ១ ដើម្បីឲ្យកម្ពុជរដ្ឋមានការលូតលាស់ចំរើនកើនឡើងជាងសម័យពីមុន ប៉ុន្តែវត្តថ្មីទាំង ២ នេះពុំទាន់មានមេគណនឹងអនុគណនៅឡើយទេ គង់នឹងមានក្នុងកាលដ៏ខ្លីខាងមុខនេះពុំខាន ។

## ការរម្ងាប់អធិករណ៍សង្ឃ

ការរម្ងាប់អធិករណ៍សង្ឃ ជានាទីរបស់គណៈសង្ឃ ៤ ប្រភេទប្រតិបត្តិការ តាមលំដាប់ថ្នាក់

១– អធិករណ៍កើតមានឡើងក្នុងវត្តណា ត្រូវគណៈសង្ឃវត្តនោះរម្ងាប់ជាមុនបង្អស់ ដោយការរាវរកហេតុខុសត្រូវឲ្យឃើញច្បាស់ហើយរម្ងាប់ដោយវិធីសម្របសម្រួលឲ្យបានស្ងប់រម្ងាប់ទៅ ។

២– បើមិនស្ងប់រម្ងាប់ទេ ត្រូវគណៈសង្ឃអនុគណជំនុំជំរះ វិនិច្ឆ័យសម្រេចសេចក្តីតាមយថាហេតុ ។

៣– បើពុំទាន់ស្ងប់រម្ងាប់ទេ ត្រូវគណៈសង្ឃមេគណជំនុំជំរះវិនិច្ឆ័យសម្រេចសេចក្តីតាមយថាហេតុ ។

